ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១១ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០០៧ | តម្លៃ ១.៥០០៛

# ប័ណ្ណកម្មសិទ្ធិដីនៅទីក្រុង ឥណទានផ្លូវការ និងវិនិយោគលើ សហគ្រាសធុនតូច និងមធ្យម

Brett Ballard និង ភីម រុនសុីណារិទ្ធិ ពិភាក្សាពីទំនាក់ទំនងរវាង ប័ណ្ណកម្មសិទ្ធិដី ឥណទានមានតំលៃថោកអាចប្រើប្រាស់បាន និងវិនិយោគលើ សហគ្រាសធុនតូច និងមធ្យម (SME) ក្នុងតំបន់ទីក្រុងចំនួន ៣ នៅកម្ពុជា ។*

អត្ថបទនេះពិភាក្សាពីទំនាក់ទំនងរវាង ប័ណ្ណកម្មសិទ្ធិដី ឥណទានមានតំលៃថោកអាចប្រើប្រាស់បាន និងវិនិយោគលើសហគ្រាសធុនតូច និងមធ្យម (SME)[១] ក្នុងតំបន់ទីក្រុងចំនួន ៣ នៅកម្ពុជា ។ ទិន្នន័យប្រមូលបាននៅចុងឆ្នាំ២០០៥ ព្រមទាំងអង្កេតមូលដ្ឋានរបស់ CDRI លើការផ្ដល់ប័ណ្ណកម្មសិទ្ធិដី នៅតំបន់ទីក្រុង បានបង្ហាញថា SMEs អាចជាប្រភពដ៏សំខាន់នៃការងារនៅភ្នំពេញ ក្រុងសៀមរាប និង សេរីសោភ័ណ្ឌ (បន្ទាយមានជ័យ) ។ ប័ណ្ណកម្មសិទ្ធិដី មានផលប៉ះពាល់យ៉ាងច្រើនលើចំនួនការងារ បើពិនិត្យពីកំលាំងវា ក្នុងការជួយជំរុញកំណើនវិនិយោគ ការបើកអាជីវកម្មថ្មី រឺការពង្រីកអាជីវកម្ម ដោយបង្កើតអារម្មណ៍កាន់កាប់ដីមានសុវត្ថិភាព និងជួយបង្កើនលទ្ធភាពទទួលបានឥណទានមានតំលៃថោកអាចប្រើប្រាស់បាន ។



*សហគ្រាសធុនតូចនិងមធ្យមមួយកន្លែង ផលិតទ្វារ និងបង្អួចធ្វើពីដែក នៅតាមផ្លូវ ២៧១ ក្រុងភ្នំពេញ*

ការសន្មត និងការទស្សទាយពីអត្ថប្រយោជន៏រំពឹងទុកនៃកម្មវិធីផ្ដល់ប័ណ្ណកម្មសិទ្ធិដី ផ្អែកជាសំខាន់លើទ្រឹស្ដីនៃកម្មសិទ្ធិអចលនទ្រព្យ ដែលចងភ្ជាប់សន្ទុះចិត្តធ្វើវិនិយោគ ទៅនឹងសុវត្ថិភាពកាន់កាប់ដី ។ អំណះអំណាងជាមូលដ្ឋាន គឺប្រជាជនតែងចង់វិនិយោគលើសកម្មភាពមានផលិតភាពខាងសេដ្ឋកិច្ច បើសិនមានទំនុកចិត្តថាខ្លួនគេ រឺអ្នកស្នងមរតករបស់ពួកគេ នឹងទទួលបានអត្ថប្រយោជន៏ពីវិនិយោគនោះ (Brando and Feder 1996; Barzel 1997) ។ ទាក់ទិននឹងការកាត់បន្ថយភាពក្រីក្រ លោក de Soto (2000) បានរកឃើញថា អ្នកក្រក្នុងប្រទេសកំពុងអភិវឌ្ឍន៏ ក៏មានទ្រព្យសកម្មច្រើនដែរ ទោះបីក្នុងទំរង់ជា "ទុនងាប់"[២] ដែលពិបាកប្រើប្រាស់ធ្វើវិនិយោគក្ដី ។ ដូច្នេះរដ្ឋាភិបាលគួរផ្ដល់កម្មសិទ្ធិលើអចលនទ្រព្យ ក្នុងទំរង់ជាប័ណ្ណកម្មសិទ្ធិស្របច្បាប់ ដែលអ្នកក្រអាចយកទៅដាក់ធានា ដើម្បីទទួលបានឥណទានសំរាប់វិនិយោគលើការកែលំអផ្ទះសំបែង SMEs រឺសកម្មភាពផលិតផ្សេងៗ ។

យោងតាមអំណះអំណាងខាងលើ ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិផ្លូវការ ដើម្បីគ្រប់គ្រងការកាន់កាប់ដី ត្រូវតែចាត់ទុកថាជាចំណែកមួយនៃវិធីសាស្ត្រផ្អែកលើទីផ្សារដើម្បីអភិវឌ្ឍន៍តំបន់ទីក្រុង នៅក្នុងបរិបទមួយដែលមានបទប្បញ្ញត្តិផ្លូវការជាច្រើន។ បទប្បញ្ញត្តិទាំងនេះរួមមាន របៀបរបបផ្ដល់

* លោកបណ្ឌិត Brett Ballard ជាទីប្រឹក្សាស្រាវជ្រាវជាន់ខ្ពស់ និងលោក ភីម រុនសុីណារិទ្ធិ ជាអ្នកស្រាវជ្រាវ នៅ CDRI ។ អត្ថបទនេះ ផ្អែកលើអង្កេតមូលដ្ឋានរបស់ CDRI លើការចុះបញ្ជីដីធ្លី ក្នុងកម្មវិធីចុះបញ្ជីដីធ្លីកម្ពុជា ។

## មាតិកា

ប័ណ្ណកម្មសិទ្ធិដីនៅទីក្រុង ........ ១
បញ្ហាប្រឈមក្នុងការគ្រប់គ្រងធនធានទឹក ........ ៥
ពាណិជ្ជកម្មកសិកម្មនៅមហាអនុតំបន់មេគង្គ ........ ៩
តាមដានសេដ្ឋកិច្ច— ស្ថានភាពក្រៅប្រទេស ........ ១៣
— ស្ថានភាពក្នុងប្រទេស ........ ១៥
— សន្ទស្សន៍សេដ្ឋកិច្ច ........ ១៨
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន វបសអ.CDRI ........ ២០

**តារាង១: ការងារក្នុង SMEs គិតតាមទីតាំង**

| ទីតាំង | ចំនួនគ្រួសារ | ពលករអចិន្ត្រៃយ៍ | | ពលករជួលតាមថ្ងៃ | | សមាជិកគ្រួសារ | | សរុប | |
|---|---|---|---|---|---|---|---|---|---|
| | | ចាប់ផ្ដើម | បច្ចុប្បន្ន | ចាប់ផ្ដើម | បច្ចុប្បន្ន | ចាប់ផ្ដើម | បច្ចុប្បន្ន | ចាប់ផ្ដើម | បច្ចុប្បន្ន |
| ភ្នំពេញ | 436 | 239 | 310 | 59 | 125 | 739 | 929 | 1037 | 1364 |
| សៀមរាប | 162 | 53 | 87 | 148 | 160 | 353 | 365 | 554 | 612 |
| សេរីសោភ័ណ្ឌ | 241 | 53 | 92 | 36 | 46 | 477 | 511 | 566 | 649 |

ឥណទានផ្លូវការ និងទីផ្សារអចលនទ្រព្យមានច្បាប់គ្រប់គ្រងល្អ (ឧ. ផែនការមេកំណត់ការប្រើប្រាស់ដី ការដាក់អនុវត្តនីតិបទប្បញ្ញត្តិបែងចែកតំបន់) ដែលជួយទ្រទ្រង់ឱ្យបរិយាកាសអាជីវកម្មមានលក្ខណៈរឹងប៉ឹងច្បាស់លាស់ ។

អង្កេតមូលដ្ឋានលើការផ្ដល់ប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុង បានធ្វើឡើងពីខែតុលា-ធ្នូ ២00៥ ។ ដោយឡែកនៅក្រុងភ្នំពេញ បានធ្វើអង្កេតលើ ១៦៦៣គ្រួសារ ក្នុងខ័ណ្ឌបីនៃខ័ណ្ឌទាំងបួនក្នុងក្រុង និងក្នុងខ័ណ្ឌទាំងបីនៅជាយក្រុង ។ ក្នុងនេះមាន ៤៣៩គ្រួសារ (២៨,៤%) រាយការណ៍ថាជាកម្មសិទ្ធិករលើ ៤៧0 SMEs រឺប្រហែល ១,0៩ SMEs ក្នុងមួយគ្រួសារ ។ នៅស្រុកសៀមរាប បានធ្វើសំភាសន៏លើ ៥៣៦គ្រួសារ ក្នុងឃុំសាលាកំរើក ដែលស្ថិតនៅតំបន់ទីក្រុង និងឃុំសៀមរាប ដែលស្ថិតនៅតំបន់ជាយក្រុង ។ ក្នុងនេះមាន ១៦៤គ្រួសារ រាយការណ៏ថា ជាកម្មសិទ្ធិករលើ ១៩២ SMEs ដូច្នេះមានគ្រួសារ ៣0,៦% ធ្វើជាម្ចាស់ SMEs ដោយគ្រួសារនីមួយៗជាមធ្យមមាន ១,១៧ SMEs ។ នៅក្នុង និងនៅជុំវិញក្រុងសេរីសោភ័ណ្ឌ បានធ្វើសំភាសន៏លើ ៥0៧គ្រួសារ នៅ ៣ឃុំ គឺ កំពង់ស្វាយ ព្រះពន្លា និង អូរអំបិល ដោយមាន ២៤១គ្រួសារ (២៨,៤%) រាយការណ៏ថាកំពុងដំណើរការ ២៨៥ SMEs រឺប្រហែល ១,១៨ SMEs ក្នុងមួយគ្រួសារ ។

តារាង១ បង្ហាញថា នៅតំបន់ទីក្រុងទាំងបី ការងារក្នុង SMEs បានកើនឡើងចាប់តាំងពីពេលធ្វើអាជីវកម្មមក ។ នៅភ្នំពេញចំនួនការងារកើនពី ២,៣៨ នៅពេលចាប់ផ្ដើម រហូតដល់ ៣,១៣ ជាមធ្យម ក្នុងមួយអាជីវកម្ម ហើយនៅសៀមរាប កើនពី ៣,៤២ ដល់ ៣,៧៨ ក្នុងមួយអាជីវកម្ម ។ នៅសេរីសោភ័ណ្ឌ វាកើនពី ២,៣៥ ដល់ ២,៦៩ ។ យោងតាម និយមន័យ SMEs ដែលផ្អែកលើចំនួនបុគ្គលិក ស្ទើរតែគ្រប់អាជីវកម្មនៅក្នុងអង្កេតនេះសុទ្ធតែជាធុនតូច ហើយមានតិចតួចណាស់ដែលអាចចាត់ទុកជាធុនមធ្យម ។ បើសន្មតថា ចំនួនគំរូតាងអង្កេតនេះអាចតំណាងឱ្យប្រជាជនទាំងអស់បាន ការអភិវឌ្ឍន៏ SMEs អាចបង្កើតការងារបានច្រើនគួរសម ។

ជាការសំខាន់គួរពិនិត្យដែរថា តើអាជីវកម្មធុនតូចនានា បានទុនមកពីណា ។ តារាង២ បង្ហាញថា នៅភ្នំពេញ ទុន ៩១,៩% បានពី "ប្រភពផ្ទាល់ខ្លួន" ។ នៅសៀមរាប និង សេរីសោភ័ណ្ឌ ក៏មានទុនប្រភពផ្ទាល់ខ្លួន ក៏រិតខ្ពស់ដែរដល់ទៅ ៨៦,១% និង ៨៥,0% ។ នៅតំបន់ទីក្រុងទាំង ៣ អ្នកចងការប្រាក់ហាក់ដូចគ្មានតួនាទីអ្វីទេ ក្នុងការផ្ដល់ទុនឱ្យ SMEs ហើយមានកំចីតែមួយចំនួនតូចប៉ុណ្ណោះដែលបានមកពីធនាគារពាណិជ្ជ ។

ការសង្កេតឃើញខាងលើ បានបំផុសសំនួរថា ហេតុអ្វីមានម្ចាស់អាជីវកម្មធុនតូចច្រើនគ្នាបែបនេះ ដែលបន្តពឹងផ្អែកលើទុនប្រភពផ្ទាល់ខ្លួន រឺរបស់ក្រុមគ្រួសារ ដើម្បីបើកអាជីវកម្មថ្មី បន្តដំណើរការ រឺពង្រីកសកម្មភាព ។ ក្នុងការសិក្សាកាលពីមុន លោក កង ច័ន្ទតារារ័ត្ន (២00៥) បានសន្និដ្ឋានថាផ្ទុយពីគោលគំនិតក្នុងទ្រឹស្ដីសេដ្ឋកិច្ចបែបបុរាណ ប្រព័ន្ធធនាគារដែលអភិវឌ្ឍបានល្អនោះ ប្រហែលមិនសូវចាំបាច់ទេសំរាប់ការបើកអាជីវកម្មថ្មី ។ សុវត្ថិភាពនៃកិច្ចសន្យាលើការខ្ចីប្រាក់ពីស្ថាប័នផ្លូវការ អាចប្រៀបផ្ទឹមគ្នាបានជាមួយទំនុកចិត្តកំរិតខ្ពស់រវាងបុគ្គល នៅក្នុងការខ្ចីបុលក្រៅផ្លូវការ ។

កត្តាមួយទៀតដែលអាចផុសឡើង គឺវិនិយោគិននានាច្រើនតែមិនច្បាស់លាស់ក្នុងចិត្ត រឺមិនសូវទុកចិត្តថា អាជីវកម្មរបស់ខ្លួនអាចរស់រានបាន ។ ឧទាហរណ៏ នៅភ្នំពេញក្នុងចំណោម SMEs ដែលបានឆ្លើយសំភាសន៏ប្រាប់ថាមិនបានខ្ចីប្រាក់ គឺមាន ៨១% បញ្ជាក់ថា ខ្លួនឯកភាពជាខ្លាំង រឺឯកភាពដែរលើហេតុផលថា ផលចំណេញរំពឹងទុកនៃអាជីវកម្ម អាចបានតិចជាងចំណាយការប្រាក់បង់លើកំចី ។ នៅសៀមរាប អ្នកគិតដូច្នេះមានដល់ទៅ ៧៥,៥% ។

លោក កង ពិនិត្យឃើញថា ក្នុងចំណោម ៦៤៨ SMEs ដែលបានឆ្លើយសំភាសន៏ មាន ៧0,១% បានចាត់ទុកកង្វះទុនថា ជាកំហិតធំបំផុតលើការពង្រីកអាជីវកម្មសំរាប់សហគ្រាសគ្រប់ធុន គ្រប់ប្រភេទ និង នៅគ្រប់ទីកន្លែង ។ ដោយសារកង្វះទុន ហាក់ដូចជាជាប់ទាក់ទងនឹង "ការរកចំណេញមិនបានគ្រប់គ្រាន់" លោក កង យល់ឃើញថា ការកសាងប្រព័ន្ធធនាគារឱ្យរឹងប៉ឹង និងកិច្ចសន្យាមានសុវត្ថិភាពល្អខាងផ្លូវច្បាប់ អាចជាកត្តាគន្លឹះសំរាប់ដោះស្រាយបញ្ហាវិនិយោគបែបនេះ ។ ដូច្នេះមានការឯកភាពជាទូទៅថាការកែលំអលទ្ធភាពទទួលបានឥណទានផ្លូវការ អាច និងគួរមានតួនាទីសំខាន់ថែមទៀតក្នុងការផ្ដល់ទុនសំរាប់វិនិយោគលើទ្រព្យសកម្មជាប់លាប់ ។

សំរាប់អាជីវកម្មបើកថ្មី និងពង្រីកបន្ថែម តំរូវការរបស់សំរាប់ដាក់ធានាគឺជាកំហិតធំមួយ ។ ក្នុងចំណោម ១៣៧ SMEs ដែលសុំខ្ចីប្រាក់ពីធនាគារ លោក កង រកឃើញថា មាន ៥២% បានទទួលការបដិសេធ ក្នុងនេះ ៦0 អាជីវកម្ម ត្រូវគេបដិសេធដោយសារខ្វះរបស់ដាក់ធានា ។ ក្នុងការសិក្សាពី

**តារាង២ : ប្រភពទុនសំរាប់ចំណាយធ្វើអាជីវកម្ម និងចំណាយក្នុងជីវភាពរស់នៅ**

| ទីតាំង | ប្រភពផ្ទាល់ខ្លួន | | គ្រួសារ | | អ្នកចងការប្រាក់ | | ធនាគារពាណិជ្ជ | | ផ្សេងទៀត | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | |
| ភ្នំពេញ | 440 | 91.9 | 29 | 6.1 | 1 | 0.2 | 4 | 0.8 | 5 | 1.0 | 479 |
| សៀមរាប | 167 | 86.1 | 16 | 8.2 | 0 | 0 | 9 | 4.6 | 2 | 1.0 | 194 |
| សេរីសោភ័ណ្ឌ | 256 | 85.0 | 26 | 8.6 | 0 | 0 | 7 | 2.3 | 12 | 4.1 | 301 |

ការផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុង មាន ៤៤,២% នៃ SMEs នៅភ្នំពេញ បាន "ឯកភាពខ្លាំងក្លា" និង "ឯកភាពដែរ" ថា តំរូវការរបស់ដាក់ធានា បានរារាំងពួកគេក្នុងការស្វែងរកកំចីពាណិជ្ជកម្ម ។ មានប្រហែល ៣០,៥% បាន "ឯកភាពខ្លាំងក្លា" រឺ "ឯកភាពដែរ" ថា ពួកគេទទួលការបដិសេធពីព្រោះខ្វះរបស់ដាក់ធានា ។ នៅសៀមរាប មាន ៤៥,១% បាន "ឯកភាពខ្លាំងក្លា" រឺ "ឯកភាពដែរ" ថា តំរូវការរបស់ដាក់ធានា បានរារាំងពួកគេក្នុងការស្វែងរកកំចីពាណិជ្ជកម្ម ។

ស្ថានភាពខាងលើ ហាក់ដូចបានប្រែប្រួលហើយ ។ យោងតាមការពិភាក្សានាពេលថ្មីៗជាមួយមន្ត្រីធនាគារ ចំនួនពាក្យសុំខ្ចីប្រាក់ និងការអនុមតិ បានកើនច្រើនណាស់ក្នុងឆ្នាំកន្លងទៅ ជាពិសេសសំរាប់ការពង្រីកអាជីវកម្ម រួមទាំង SMEs ។ មានសេចក្តីរាយការណ៍ជាច្រើនបញ្ជាក់ថា វិនិយោគិននៅតែរារែកទៅខ្ចីប្រាក់ពីធនាគារដើម្បីបើកអាជីវកម្មថ្មី ពីព្រោះពួកគេមិនសូវទុកចិត្តលើផលចំណេញបានពីវិនិយោគ ។ ដូច្នេះការបើកអាជីវកម្មថ្មីនៅតែបន្តពឹងផ្អែកជាសំខាន់លើទុនផ្ទាល់ខ្លួន រឺខ្ចីពីសាច់ញាតិ មិត្តភក្តិ ។ ប៉ុន្តែនៅពេលអាជីវកម្មមានដំណើរការ ហើយអាជីវករមើលឃើញប្រាក់ចំណូលហូរចូលយ៉ាងទៀងទាត់ និងអាចទស្សទាយបាន ពួកគេហាក់ដូចកាន់តែហ៊ានទៅខ្ចីប្រាក់ពីធនាគារពាណិជ្ជ យកមកពង្រីកអាជីវកម្ម ។

ការប្រែប្រួលឥរិយាបទក្នុងការទៅខ្ចីប្រាក់ពីធនាគារពាណិជ្ជ ហាក់ដូចទើបកើតមានថ្មីៗនេះទេ ។ នៅពេលបរិយាកាសធ្វើអាជីវកម្មនៅកម្ពុជាប្រែប្រួលប្រសើរឡើង ហើយវិនិយោគិនក៏កាន់តែទុកចិត្តលើវិស័យធនាគារ និន្នាការមានកំណើនតំរូវការឥណទានសំរាប់គោលដៅផ្សេងៗ ប្រហែលនឹងបន្តទៅមុខទៀត ។ ដោយសារធនាគារត្រូវការ "ប្លង់រឹង" ក្នុងការផ្តល់កំចីដូច្នេះប័ណ្ណកម្មសិទ្ធិដី ប្រហែលអាចជួយបង្កើនកំចីសំរាប់ដោះស្រាយចំណាយប្រើប្រាស់ និងធ្វើអាជីវកម្ម ។ គួរកត់សំគាល់ជាសំខាន់ថា កំណើនបែបនេះ អាចមិនមែនផុសចេញពីប័ណ្ណកម្មសិទ្ធិដីតែមួយមុខនោះទេ ប៉ុន្តែមានកត្តាជាច្រើន ដែលគួបផ្សំគ្នាបង្កើតបានជាវដ្តមួយដ៏ប្រសើរនៃការអភិវឌ្ឍន៍ និងការរីកចំរើន ។ កត្តាទាំងនេះមានជាអាទិ៍ បទពិសោធន៍/ជំនាញ (គឺ សហគ្រិនភាព) សុវត្ថិភាព/ស្ថិរភាពនយោបាយ ធនាគារដែលចង់និងចេះផ្តល់កំចី (គឺ ការផ្គត់ផ្គង់ឥណទាន) និងប្រជាជនមានទំនុកចិត្តលើស្ថាប័នធនាគារ ។ ការអភិវឌ្ឍន៍ទីផ្សារឥណទាន និងវិស័យអាជីវកម្ម ហាក់ដូចឈរលើកត្តាដូចគ្នាជាច្រើន ក្នុងរឿងទំនុកចិត្តលើស្ថាប័ន ។ នៅពេលកត្តាទាំងនេះកើតមានជាក់ស្តែង និងដំណើរការមានប្រសិទ្ធភាពល្អ វាជួយឱ្យសហគ្រិននានា អាចទស្សទាយកាន់តែត្រឹមត្រូវពីផលចំណេញលើវិនិយោគ ។

ក្នុងអង្កេតលើការផ្តល់ប័ណ្ណកម្មសិទ្ធិដីនៅតំបន់ទីក្រុង មានភស្តុតាងជាច្រើន ដែលហាក់ដូចបញ្ជាក់គាំទ្រដល់ការសង្កេតឃើញពីការផ្លាស់ប្តូរឥរិយាបទទាក់ទិននឹងកំចីពីធនាគារពាណិជ្ជ ។ តារាង ៣ មានចុះសង្ខេបពីកំចីជាប់ទាក់ទិនអាជីវកម្ម និងប្រភពរបស់វា ។ នៅភ្នំពេញ ក្នុងចំណោម ៥០២កំចី ដែលគេរាយការណ៍ថា បានកើតមាននៅចន្លោះពេលរវាងការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ២០០៣ នឹងចុងឆ្នាំ២០០៥ គឺមាន ១៨០ (រឺ ៣៥,៦%) ជាកំចីសំរាប់បើកអាជីវកម្មថ្មី ដោះស្រាយដំណើរការ និងពង្រីកអាជីវកម្ម ។ នៅសៀមរាប កំចីសំរាប់បំរើអាជីវកម្មមាន ៣៨,៥% ហើយនៅសេរីសោភ័ណ្ឌ មាន ៣៣,៨% ។ ចំណុចគួរយកចិត្តទុកដាក់ គឺសំរាប់កំចីបំរើអាជីវកម្ម ធនាគារអេស៊ីលីដាផ្តល់បាន ៤១,១% នៅភ្នំពេញ ៤៨,០% នៅសៀមរាប និង ៣៦,៧% នៅសេរីសោភ័ណ្ឌ ។ បើគិតទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ផង ស្ថាប័នផ្តល់កំចីផ្លូវការហាក់ដូចដើរតួនាទីសំខាន់ ក្នុងការផ្តល់ទុនសំរាប់សកម្មភាពអាជីវកម្ម ។

ស្របនឹងកំណើនយ៉ាងទៀងទាត់ជារៀងរាល់ឆ្នាំនៃចំនួនកំចីពីគ្រប់ប្រភពនៅក្នុងតំបន់ទីក្រុងទាំង ៣ ចំនួនកំចីពីប្រភពផ្លូវការ (គឺ MFIs និងធនាគារពាណិជ្ជ) ក៏កើនឡើងដែរ ។ នៅភ្នំពេញ កំចីពីប្រភពផ្លូវការមាន ៣៧,៥% នៅឆ្នាំ២០០៣ និង ៤១,៧% នៅឆ្នាំ២០០៥ ។ នៅសៀមរាប និងសេរីសោភ័ណ្ឌ ថ្វីបើចំនួនកំចីកើនឡើងជារៀងរាល់ឆ្នាំក្តី ប៉ុន្តែចំនួនកំចីផ្លូវការគិតជាភាគរយបានថយចុះ ។ នៅសៀមរាប វាថយចុះពី ៥៤,១% នៅ

**តារាង៣: ប្រភពកំចីសំរាប់សកម្មភាពជាប់ទាក់ទិនអាជីវកម្ម**

| | សាច់ញាតិ | មិត្តភក្តិ | អ្នកចងការប្រាក់ | NGO | MFI | អេស៊ីលីដា | សរុប |
|---|---|---|---|---|---|---|---|
| ភ្នំពេញ | 147 | 32 | 97 | 23 | 27 | 172* | 502* |
| *ចាប់បើកថ្មី* | 9 | 3 | 10 | 5 | 7 | 23 | 60 |
| *ធាតុចូល/ដំណើរការ* | 14 | 2 | 4 | 2 | 1 | 16 | 40 |
| *ពង្រីក* | 14 | 4 | 15 | 5 | 7 | 35 | 80 |
| សៀមរាប | 49 | 7 | 37 | 5 | 26 | 71 | 195 |
| *ចាប់បើកថ្មី* | 3 | 0 | 2 | 0 | 5 | 10 | 20 |
| *ធាតុចូល/ដំណើរការ* | 4 | 0 | 4 | 0 | 2 | 6 | 16 |
| *ពង្រីក* | 0 | 1 | 6 | 1 | 8 | 23 | 39 |
| សេរីសោភ័ណ្ឌ | 23 | 5 | 54 | 7 | 15 | 41 | 145 |
| *ចាប់បើកថ្មី* | 3 | 1 | 7 | 0 | 0 | 4 | 15 |
| *ធាតុចូល/ដំណើរការ* | 3 | 0 | 6 | 1 | 4 | 4 | 18 |
| *ពង្រីក* | 1 | 0 | 5 | 0 | 0 | 10 | 16 |

* តួលេខនេះមានបូកទាំង កំចីមួយរបស់ធនាគារកាណាឌីយ៉ាផង

ឆ្នាំ២០០៣ មកត្រឹម ៤៧,០% នៅឆ្នាំ២០០៥ ថ្វីបើចំនួនជាក់ស្តែងនៃកំចីបានកើនទ្វេដិតមួយជាពីរក្តី ។

ចំពោះតួលេខឥណទានទាក់ទិនអាជីវកម្ម និងតួលេខកំចីផ្តល់ឱ្យ SMEs គឺហាក់ដូចមិនរលូនគ្នាទេ ។ ទិន្នន័យលើកំចីអាជីវកម្ម បង្ហាញនូវកំណើនទឹកប្រាក់កំចីពីវិស័យផ្លូវការ ប៉ុន្តែទិន្នន័យ SME បង្ហាញថា វិស័យផ្លូវការមានតួនាទីតិចតួចណាស់ក្នុងការផ្តល់ទុនសំរាប់ការបើកអាជីវកម្មថ្មី កិច្ចដំណើរការ និងការពង្រីកសកម្មភាព ។ តួលេខមិនស៊ីគ្នានេះ អាចពន្យល់បានច្រើនយ៉ាង ។

ទី១ ទិន្នន័យលើកំចីទាំងអស់ មានរួមបញ្ចូលសកម្មភាពជាប់ទាក់ទិនអាជីវកម្មគ្រប់ប្រភេទ ទាំងតូច ទាំងធំ ក្នុងនេះមានខ្លះប្រើបុគ្គលិករហូតដល់ជាង ១០នាក់ ចំណែកឯទិន្នន័យលើ SMEs កត់ត្រាសឹងតែសុទ្ធសាធនូវសហគ្រាសធុនតូចដែលប្រើបុគ្គលិកតិចជាង ៥នាក់ ។ ជាទូទៅអាជីវកម្មធំៗតែងត្រូវការទុនច្រើនៗ ដូច្នេះក៏មានទឹកចិត្តជាងក្នុងការទៅខ្ចីប្រាក់ពីស្ថាប័នផ្លូវការ ព្រមទាំងមានលទ្ធភាពច្រើនជាង SMEs ដើម្បីសងការប្រាក់ក៏រិតខ្ពស់របស់ធនាគារពាណិជ្ជ ក៏ដូចជាសងបំណុលតាមតារាងពេលដ៏តឹងរ៉ឹង ។

ទី២ ទិន្នន័យលើឥណទាន គ្របដណ្តប់តែលើចន្លោះពេលពីការបោះឆ្នោតតំណាងរាស្ត្រឆ្នាំ២០០៣ ដល់ចុងឆ្នាំ២០០៥ ចំណែកឯទិន្នន័យសំរាប់ SMEs គ្របដណ្តប់តាំងពីឆ្នាំ១៩៨០ ។ គួរចងចាំថា ទោះបីនៅដើមទសវត្សរ៍២០០០ ហើយក្តី ក៏វិស័យធនាគារមិនទាន់ចូលរួមច្រើនទេក្នុងសកម្មភាពផ្តល់កំចី ។ ឧទាហរណ៍ ឯកសារមួយផ្សព្វផ្សាយនៅឆ្នាំ២០០៣ របស់កម្មវិធីអភិវឌ្ឍន៍វិស័យឯកជនតំបន់ទន្លេមេគង្គ (MPDF) បានលើកពីហេតុផល ១៥យ៉ាង ដែលធនាគារមិនបានផ្តល់កំចីឱ្យ SMEs រហូតមកដល់ពេលនោះ ។ អ្នកស្រាវជ្រាវ Keith Carpenter និង អ៊ូច ច័ន្ទតារានី (២០០៦) បានរកឃើញថា ហេតុផលចំបងមួយនៃការផ្តល់កំចីបែបស្ទើកស្រពន់នេះ គឺ ធនាគារមិនចង់ឱ្យខ្ចីតែម្តង ។ ដោយសារ SMEs ៦១,៨% នៅភ្នំពេញ និង ៦៤,៦% នៅសៀមរាប បានធ្វើអាជីវកម្មតាំងពីមុនឆ្នាំ២០០៣ ដូច្នេះទុនស្ទើរតែទាំងអស់សុទ្ធសឹងបានមកពីប្រភពផ្ទាល់ខ្លួន រឺសាច់ញាតិ ។

ទី៣ កត្តាដែលអាចសំខាន់ជាងគេ គឺ កំចីសឹងតែទាំងអស់ដែលគេរាយការណ៍ថាបានមកពីវិស័យពាណិជ្ជកម្ម សុទ្ធតែផ្តល់ដោយធនាគារអេស៊ីលីដា ដែលមានសាខានៅពាសពេញប្រទេស ។ ជាក់ស្តែងមានតែកំចីមួយប៉ុណ្ណោះ ដែលបានមកពីធនាគារកាណាឌីយ៉ា ។ អេស៊ីលីដាមានប្រវត្តិជា NGO ខាងមីក្រូហិរញ្ញវត្ថុ និងមានរបៀបរបបផ្តល់កំចីផ្អែកទៅតាមគោលដៅខាងសង្គមកិច្ច គឺខុសពីធនាគារពាណិជ្ជឯទៀតៗនៅកម្ពុជា ។ បើសិនដកអេស៊ីលីដាចេញពីវិស័យធនាគារផ្លូវការ គេឃើញថាធនាគារពាណិជ្ជឯទៀតមិនបានផ្តល់កំចីទេ ទោះសំរាប់គោលដៅអ្វីក៏ដោយ រួមទាំងសកម្មភាពអាជីវកម្មផង ។ ដូច្នេះ ក្រៅពីកំចីមួយចំនួនតូចរាយការណ៍ដោយ MFIs សកម្មភាពអាជីវកម្មភាគច្រើន នៅតែផ្តល់ទុនដោយប្រភពក្រៅផ្លូវការ ក្នុងនេះមានទាំងអ្នកចងការប្រាក់ផងដែរ ។ រឿងនេះដូចគ្នាខ្លាំងណាស់នឹង SMEs ដោយទុនភាគច្រើនបានពីប្រភពផ្ទាល់ខ្លួន រឺសាច់ញាតិដែលជាទូទៅផ្តល់កំចីឱ្យដោយមិនយកការប្រាក់ រឺទាមទារឱ្យដាក់របស់ធានាឡើយ ។ មានតែអ្នកចងការប្រាក់ទេ ដែលយកការប្រាក់ ។ ដោយសារម្ចាស់ SMEs ហាក់បារម្ភច្រើនថា ចំណាយលើការប្រាក់វាឡើងខ្ពស់ជាងចំណូលអាចរកបាន ពួកគេតែងជៀសវាងមិនខ្ចីបុលពីអ្នកចងការប្រាក់ទេ ប៉ុន្តែមានអាជីវកម្មធំៗខ្លះ ហ៊ានខ្ចីពីប្រភពនេះ ។

សកម្មភាពឥណទានពាក់ព័ន្ធនឹងវិស័យធនាគារផ្លូវការ គឺឃើញមានគេរាយការណ៍ប្រាប់ច្រើនក៏ពិតមែន ប៉ុន្តែគេត្រូវពុះពារទៅមុខទៀតច្រើនណាស់មុននឹងវិនិយោគិន SMEs និងវិស័យធនាគារជាប្រពៃណីនេះ ទទួលស្គាល់គ្នាទាំងស្រុងទៅវិញទៅមក ។ ថ្វីបើការលំបាកទាក់ទិននឹងតំរូវការរបស់ធានាអាចដោះស្រាយបានមួយកំរិតធំដោយប្រើប័ណ្ណកម្មសិទ្ធិដីក្តី ប៉ុន្តែទិន្នន័យបង្ហាញច្បាស់ថា វិនិយោគិនត្រូវជួបកំហិតជាច្រើនទៀតដើម្បីទទួលបានកំចី ។ ដូចបានពិភាក្សាខាងលើ អត្រាចំណេញរបស់អាជីវកម្មធៀបនឹងអត្រាការប្រាក់មានសារៈសំខាន់ខ្លាំងណាស់ ។ ទោះបីអេស៊ីលីដា ក៏មានអត្រាការប្រាក់ខ្ពស់ណាស់ដែរ លើកំចីតូចៗនៅឆ្នាំ២០០៤-២០០៥ ។[៤] ដូច្នេះ ទោះបីប័ណ្ណកម្មសិទ្ធិដីអាចជួយបង្កើនលទ្ធភាពទទួលបានកំចីពាណិជ្ជកម្ម ដោយដើរតួជារបស់សំរាប់ដាក់ធានាក្តី ប៉ុន្តែគេត្រូវដោះស្រាយកំហិតជាច្រើនទៀត ទើបអាចប្រើប័ណ្ណនេះបានពេញលេញ ។ ប័ណ្ណកម្មសិទ្ធិដីអាចចាំបាច់ក៏ពិតមែន ប៉ុន្តែវាមិនគ្រប់គ្រាន់ទេសំរាប់ជំរុញកំណើនវិនិយោគដើម្បីបើកថ្មី និងពង្រីក SMEs ។

## សន្និដ្ឋាន

ថ្វីបើទិន្នន័យឥណទានបង្ហាញថា ពីឆ្នាំ២០០៣-២០០៥ ប្រជាជនបានបង្កើនការខ្ចីប្រាក់ពីវិស័យពាណិជ្ជកម្មសំរាប់គោលដៅផ្សេងៗ រួមទាំងអាជីវកម្មផងក្តី ប៉ុន្តែវាឆាប់ពេកណាស់នឹងធ្វើការសន្និដ្ឋានថា ទំនោរខ្ចីប្រាក់កាន់តែច្រើនពីវិស័យផ្លូវការឥឡូវនេះបានរីកទៅដល់ SMEs ។ ហេតុផលមួយក្នុងនេះ គឺកំចីពាណិជ្ជកម្មពីឆ្នាំ២០០៣-២០០៥ ដែលបានរាយការណ៍ឡើង សុទ្ធតែផ្តល់ដោយអេស៊ីលីដា ដែលមានបេសកកម្មគួរឱ្យកោតសរសើរ ប៉ុន្តែខុសគ្នាបន្តិចពីធនាគារពាណិជ្ជឯទៀតៗ ។ ទោះយ៉ាងនេះក្តី មានគេរាយការណ៍បញ្ជាក់ថា យ៉ាងហោចណាស់ក៏មានធនាគារពាណិជ្ជមួយ ដែលបានបង្កើនកំចីបែបនេះចាប់ពីពេលធ្វើអង្កេត រហូតដល់ចុងឆ្នាំ២០០៥ ដោយចាប់ផ្តើមបង្កើនការផ្តល់កំចីសំរាប់ពង្រីក SMEs ។ ជាក់ស្តែងធនាគារ ANZ Royal ដែលជាចំណូលថ្មីក្នុងទីផ្សារធនាគារ ហាក់ដូចមានបំណងនិងអាចផ្តល់កំចីដល់អតិថិជនច្រើនបែបយ៉ាង រួមទាំង SMEs ផងដែរ ។ កំចីទាំងនេះ អាចយកទៅប្រើសំរាប់បើកអាជីវកម្មថ្មី យោងតាមល្បឿនកំណើនទំនុកចិត្តលើស្ថាប័នធនាគារ និងការរក្សាបរិយាកាសឱ្យបន្តអំណោយផលល្អដល់វិស័យអាជីវកម្ម ។

ដោយសារ SMEs ជាប្រភពការងារដ៏សំខាន់ កំណើនចំនួន SMEs រឺការពង្រីកទំហំ SMEs បច្ចុប្បន្ន អាចមានផលប៉ះពាល់ច្រើនណាស់ដល់ចំនួនការងារសរុប ។ ក្នុងនេះ ប័ណ្ណកម្មសិទ្ធិដីអាចក្លាយជាកាតាលីករដ៏សំខាន់ ដោយផ្តល់ឱ្យវិនិយោគិននូវអារម្មណ៍កាន់កាប់ដីមានសុវត្ថិភាព និងរបស់សំរាប់ដាក់ធានានៅពេលស្វែងរកកំចីផ្លូវការ សំរាប់បើកអាជីវកម្មថ្មី រឺពង្រីកអាជីវកម្ម ។ ការសន្និដ្ឋាននេះ នឹងយកទៅផ្ទៀងផ្ទាត់បញ្ជាក់ឡើងវិញនៅពេលធ្វើអង្កេតមូលដ្ឋានសំរាប់តាមដានបន្ត ។

## កំណត់សំគាល់

១. ក្នុងការសិក្សាមួយ (Kang 2005) គេបែងចែកសហគ្រាសជា ៣ ប្រភេទ គឺ ធុនមីក្រូ (ប្រើកម្មករ ១-២នាក់) ធុនតូច (កម្មករ ៣-៥នាក់) និង ធុនមធ្យម (កម្មករ ១០-១០០នាក់) ។

២. "ពួកគេមានផ្ទះតែគ្មានប័ណ្ណកម្មសិទ្ធិ មានដំណាំតែគ្មានកិច្ចសន្យា មានអាជីវកម្មតែគ្មានលក្ខន្តិកៈ" ។

៣. អង្កេតមិនបានធ្វើនៅខ័ណ្ឌ ៧មករា ទេ ។

៤. សូមអានរបាយការណ៍ប្រចាំឆ្នាំ នៅ www.acledabank.com.kh ។

*សូមមើលឯកសារយោងក្នុងអត្ថបទជាភាសាអង់គ្លេស*

# បញ្ហាប្រឈម ក្នុងការគ្រប់គ្រង ធនធានទឹករបស់ សហគមន៍កសិករប្រើប្រាស់ទឹក

*គីម ស៊ាន ស៊ូម៉ាត្រា និង ខៀវ ដារ៉ាវី រាយការណ៍ពីការវាយតំលៃខាងសង្គមកិច្ចនៃការគ្រប់គ្រងធនធានទឹកនៅតំបន់ទន្លេសាប និងពិភាក្សាពីបញ្ហាការបែងចែកទឹក ការចូលរួមរបស់ប្រជាជន ដំណើរការប្រព័ន្ធស្រោចស្រព ការថែទាំជួសជុល និងការដោះស្រាយទំនាស់ ដែលអាចជះឥទ្ធិពលដល់អភិបាលកិច្ចទឹក ។**

> *កសិករម្នាក់នៅស្រុកស្រះរាំង ខេត្តបន្ទាយមានជ័យ បានលើកឡើងថា: "ជារៀងរាល់ឆ្នាំ ការធ្វើស្រែ គឺជាល្បែងភ្នាល់គ្នាជាមួយទឹកភ្លៀង ។ យើងមិនដឹងថានឹងបានផលប៉ុណ្ណាទេ "*

> *សមាជិកក្រុមប្រឹក្សាឃុំនៅស្រុកស្រះរាំង ខេត្តបន្ទាយមានជ័យ ក៏បានលើកឡើងថា: "កសិករកម្ពុជាមានជីវភាពក្រីក្រ ពីព្រោះគ្មានទឹកគ្រប់គ្រាន់សំរាប់ធ្វើស្រែ"*

សំដីខាងលើ បង្ហាញពីទិដ្ឋភាពសំខាន់មួយនៃបញ្ហាទឹកនៅក្នុងវិស័យកសិកម្ម ដែលប្រជាជនកម្ពុជាជាង ៨០% ត្រូវពឹងផ្អែកលើវាដោយផ្ទាល់ រឺដោយប្រយោល ។ ដោយដឹងពីតួនាទីដ៏សំខាន់នៃប្រព័ន្ធស្រោចស្រពសំរាប់ការអភិវឌ្ឍន៍ជាតិ រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ជាពិសេសលើប្រព័ន្ធនេះ ពីព្រោះវាមានសក្តានុពលខ្លាំងក្លា ផ្តល់ផលប្រយោជន៍ដល់ប្រជាកសិករខ្មែរ ។ ប្រព័ន្ធស្រោចស្រពជួយឱ្យកសិករមិនសូវពឹងផ្អែកលើទឹកភ្លៀង និងញាំងឱ្យផលស្រូវវស្សាអាចទស្សទាយបានច្បាស់គួរសម ។ ទន្ទឹមគ្នានេះ កសិករអាចដាំដុះបាន ២-៣ដង ក្នុងមួយឆ្នាំ ។ ស្រូវអង្ករ ជាអាហារមូលដ្ឋានដ៏ចំបង ហើយជួនកាលក្លាយជា ដំណាំលក់យកប្រាក់ដែលជាប្រភពចំបង ផ្តល់ការងារឱ្យប្រជាជនកម្ពុជា ហើយកំណើននៅក្នុងវិស័យនេះមិនត្រឹមតែនាំឱ្យមានកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយធ្វើឱ្យប្រាក់ចំណូលបែងចែកបានល្អផង ។ លើសពីនេះ ប្រព័ន្ធស្រោចស្រព ជួយឱ្យកសិករអាចដាំដុះដំណាំលក់យកប្រាក់បានច្រើនប្រភេទ ដូចជា បន្លែ ឪឡឹក និង ពោត ជាដើម ។

ការកសាងប្រព័ន្ធស្រោចស្រពតែមួយមុខ មិនអាចគ្រប់គ្រាន់ទេ ហើយគេត្រូវពិនិត្យពីបញ្ហាពាក់ព័ន្ធនឹងអភិបាលកិច្ច ដើម្បីឱ្យប្រព័ន្ធស្រោចស្រពដំណើរការបានជោគជ័យ ។ អត្ថបទនេះ រាយការណ៍ពីការវិភាគខាងសង្គមកិច្ច លើការគ្រប់គ្រងធនធានទឹកនៅ ១៨ទំនប់ទឹក ក្នុងតំបន់បឹងទន្លេសាប ។ យោងតាមលទ្ធផលជាដំបូងនៃការសិក្សា អត្ថបទនឹងពិភាក្សាពីបញ្ហាការបែងចែកទឹក ការចូលរួមរបស់ប្រជាជន ដំណើរការ ការថែទាំជួសជុល និងការដោះស្រាយទំនាស់ ដែលអាចជះឥទ្ធិពលដល់អភិបាលកិច្ចទឹក ។

## ប្រវត្តិសហគមន៍កសិករប្រើប្រាស់ទឹក (FWUC)

តាមការប៉ាន់ស្មាន ៩០% នៃប្រព័ន្ធស្រោចស្រពកម្ពុជា បានកសាងឡើងនៅអំឡុងរបបប៉ុលពត ។ ក្នុងនេះ សំណង់ជាច្រើន មិនបានរចនារៀបចំល្អទេ ហើយក្រោយរបបប៉ុលពតដួលរលំនៅឆ្នាំ១៩៧៩ ក៏ត្រូវបោះបង់ចោលគ្មានដំណើរការអ្វីទាំងអស់ ធ្វើឱ្យផលិតកម្មស្រូវត្រូវពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង ។ ស្រែភាគច្រើនប្រើប្រាស់ទឹកភ្លៀង ហើយភ្លៀងតែងតែធ្លាក់មិនទៀងទាត់ទេ ។ បើសិនក្រមានភ្លៀងនៅដើមរដូវវស្សា ការដាំដុះនឹងត្រូវរអាក់រអួល រឺក៏ខូចអស់មួយរដូវពេញតែម្តង ។ ម្យ៉ាងទៀត មានកូនរដូវប្រាំងមួយនៅចំកណ្តាលរដូវវស្សា ដែលជាពេលស្រូវត្រូវការទឹកខ្លាំងបំផុត ហើយអាចខូចខាតទាំងអស់បាន ។

ដើម្បីសំរួលបញ្ហាផ្គត់ផ្គង់ទឹក និងសំរេចបានកំណើនកសិកម្ម រដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់លើប្រព័ន្ធស្រោចស្រព ដោយកសាងរចនាសម្ព័ន្ធ និងពង្រឹងប្រព័ន្ធគ្រប់គ្រង ។ ចាប់ពីឆ្នាំ១៩៩៣មក ការគ្រប់គ្រងធនធានទឹក បាននឹងកំពុងផ្ទេរពីប្រព័ន្ធគ្រប់គ្រងដោយថ្នាក់ជាតិ ទៅអាជ្ញាធរមូលដ្ឋាន ។ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ បានណែនាំឱ្យប្រើ "ការគ្រប់គ្រងដំណើរការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពដោយមានការចូលរួម (PIMD)" ដែលផ្តោតលើការចូលរួមរបស់ប្រជាជនមូលដ្ឋាន និងតំរូវឱ្យមានការសំរេចចិត្តនៅកំរិតទាបបំផុតដែលសមស្រប ដោយមានការពិគ្រោះយោបល់ជាមួយប្រជាជន និងការចូលរួមពីអ្នកប្រើប្រាស់ ក្នុងការធ្វើផែនការ និងអនុវត្តន៍គំរោង (Dublin Statement on Water and Sustainable Development) ។ គេបានអះអាងថា ការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការងារអភិវឌ្ឍន៍ អាចធ្វើឱ្យគំរោងមានការទទួលស្គាល់ជាលក្ខណៈនយោបាយ និងសង្គម (Schumacher 1973; McDonald and Kay 1988; Ojendal 2000) ពីព្រោះប្រជាជនអាចប្រាប់ពីតំរូវការ និងញាំងឱ្យការងារដើរស្របតាមផលប្រយោជន៍របស់ខ្លួន ។ ដូច្នេះ វាធ្វើឱ្យប្រជាជនមូលដ្ឋានកាន់តែចាប់អារម្មណ៍ថា ខ្លួនជាម្ចាស់លើគំរោង (Moote et al. 1997) ។ ចំណេះដឹងបច្ចេកទេសតាំងពីបុរាណរបស់ប្រជាជនមូលដ្ឋាន អាចមានតំលៃខ្លាំងណាស់សំរាប់ការគ្រប់គ្រងធនធានទឹក តាំងពី ការប្រមូលយកទឹក ការគ្រប់គ្រងអាងទឹក រឺប្រព័ន្ធស្រោចស្រព ។

PIMD នៅកម្ពុជា ជាសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ដែលបានបង្កើតឡើង ដើម្បីគ្រប់គ្រងប្រព័ន្ធស្រោចស្រពតាមបែបប្រជាធិបតេយ្យ ។ យោងតាមច្បាប់ជាធរមាន កសិករនៅក្នុងតំបន់ស្រោចស្រព (តំបន់ទទួលបានទឹកពីប្រព័ន្ធស្រោចស្រព) ត្រូវដាក់ពាក្យសុំចូលជាសមាជិក ដើម្បីអាចប្រើប្រាស់ទឹកពីទំនប់ស្តុកទឹក ដោយក្នុងនេះ កសិករត្រូវយល់ព្រមបង់វិភាគទានជាកំរៃសេវា ។ ម្យ៉ាងទៀត FWUC មានសិទ្ធិផាកពិន័យ រឺដាក់ទណ្ឌកម្មដល់អ្នកដែលមករំខាន រឺបំផ្លាញផលប្រយោជន៍របស់ FWUC រឺរបស់ពួកសមាជិកសហគមន៍ (MOWRAM, 2000) ។ ប៉ុន្តែគេមិនច្បាស់ទេថា FWUC អាចធ្វើការបានរលូនប៉ុណ្ណាជាមួយនឹង របៀបរបបដែលមានស្រាប់ យោងតាមក្រឹត្យក្រម ជំនឿ ធនធានសង្គម (ទំនុកចិត្ត និង បណ្តាញ) និងនយោបាយនៅក្នុងមូលដ្ឋាន ។ លោក Ojendal (2000) បានដាស់តឿនថា ការគ្រប់គ្រងធនធានមួយដែលធ្លាប់តែទទួលបានដោយឥតបង់ថ្លៃគឺ "យ៉ាប់

---

* លោក គីម ស៊ាន ស៊ូម៉ាត្រា និង កញ្ញា ខៀវ ដារ៉ាវី ជាអ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ។ អត្ថបទនេះ ផ្អែកលើការរកឃើញជាដំបូង១នៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវគ្រប់គ្រងធនធានទឹក ។

បន្តិច" ហើយវាមិនច្បាស់ទេថា តើស្ថាប័នមូលដ្ឋាន ដូចជា សហគមន៍កសិករប្រើប្រាស់ទឹកជាដើម អាចមានបែបបទយ៉ាងណាក្នុងការគ្រប់គ្រងធនធានទឹក ដើម្បីឱ្យវាធានាបាននូវកំណើនសេដ្ឋកិច្ច សមធម៌ក្នុងសង្គម និងចីរភាពខាងហិរញ្ញវត្ថុ និងបរិស្ថាន ។

## លទ្ធផលរកឃើញ

*ការបែងចែកទឹកនៅក្នុងប្រព័ន្ធស្រោចស្រពនីមួយៗ*

FWUC ត្រូវប្រឈមនឹងបញ្ហាធំៗជាច្រើនលើការបែងចែកទឹកក្នុងតំបន់ទំនប់ទឹកទៅឱ្យកសិករជាសមាជិក (តាមធម្មតា គឺកសិករធ្វើស្រែប្រាំង) ។ រដូវប្រាំងនៅកម្ពុជា មានរយៈពេលប្រហែល ៣ខែ ចាប់ពីខែធ្នូ ដល់ ខែមីនា ហើយជារឿយៗ គេពុំមានទឹកគ្រប់គ្រាន់សំរាប់ស្រោចស្រពរហូតដល់រដូវច្រូតកាត់ទេ ។ នៅពេលមើលឃើញដំណាំរបស់ខ្លួនអាចខូចខាត ដោយសារកង្វះទឹក កសិករចង់បញ្ចូលទឹកឱ្យបានច្រើនទៅក្នុងស្រែរបស់ខ្លួន មុនពេលស្ទឹងអូរវារីងអស់ ដូច្នេះហើយក៏មានការប្រកួតប្រជែងគ្នាយ៉ាងតឹងតែង ។ នៅឯទំនប់ទឹកត្រពាំងត្របែក នៅខេត្តកំពង់ឆ្នាំង ក្នុងកិច្ចប្រឹងប្រែងបែងចែកទឹកឱ្យបានស្មើភាពទៅឱ្យសមាជិកខ្លួន FWUC បានសុំជំនួយពីក្រុមប្រឹក្សាឃុំសង្កាត់ ដែលបានចេញលិខិតណែនាំកសិករ ឱ្យបែងចែកទឹកគ្នាប្រើប្រាស់ឱ្យបានស្មើៗគ្នា ។ ប៉ុន្តែកសិករ មិនយកចិត្តទុកដាក់ដល់ការរៀបចំនោះទាល់តែសោះ ហើយពោលថាៈ "យើងហូបបាយ មិនមែនហូបក្រដាសទេ" ។

តារាងពេលផ្គត់ផ្គង់ទឹក ក៏ជាបញ្ហាមួយធំដែរសំរាប់ FWUC ភាគច្រើន ។ នៅខេត្តបាត់ដំបង មានសហគមន៍កសិករប្រើប្រាស់ទឹកមួយ បានផ្អែកលើបទពិសោធន៍កន្លងមក ច្នៃចេញជាបែបបទមួយ ដែលពួកគេគិតថាអាចជួយឱ្យពួកគេបែងចែកទឹកបានល្អ ។ តាមបែបបទនោះ នៅពេលគេបើកទ្វារទឹកធំ ហើយមានទឹកក្នុងប្រឡាយមេ កសិករនៅខ្សែទឹកខាងក្រោម អាចប្រើប្រាស់ទឹកធ្វើស្រែបានមុន រហូតដល់ស្រូវធំធាត់លែងត្រូវការទឹក ។ បន្ទាប់មក កសិករនៅខ្សែទឹកខាងលើ អាចចាប់ផ្ដើមដាំដុះបាន ។ ប៉ុន្តែផែនការនេះបានទទួលបរាជ័យ ។ កសិករមិនយកចិត្តទុកដាក់នឹងបែបបទនេះទេ ហើយអ្នកនៅខ្សែទឹកខាងលើបានកសាងទំនប់បណ្ដោះអាសន្នកាត់ប្រឡាយមេ ដើម្បីបង្វែរទឹកចូលទៅក្នុងស្រែពួកគេ នៅពេលទ្វារទឹកបើក ។ សហគមន៍កសិករប្រើប្រាស់ទឹកមិនអាចធ្វើអ្វីកើតទេ បានត្រឹមតែឈរមើលប៉ុណ្ណោះ ។

*ការបែងចែកទឹកពីប្រព័ន្ធស្រោចស្រពមួយ ទៅប្រព័ន្ធស្រោចស្រពមួយទៀត*

បញ្ហាប្រឈមមួយទៀតរបស់ FWUC គឺជាការផ្ទេរទឹកពីប្រព័ន្ធស្រោចស្រពមួយទៅកាន់ប្រព័ន្ធមួយទៀត នៅក្នុងដែនរងទឹកភ្លៀងតែមួយ ដោយសារភាពមិនស៊ីគ្នារវាងចំណុះដែនរងទឹកភ្លៀង នឹងតំរូវការទឹក ។ ទំនប់ទឹកកសាងនៅទសវត្សរ៍១៩៨០ និង ១៩៩០ ត្រូវបានរចនារៀបចំ ផ្ដល់មូលនិធិ និងកសាងឡើង ដោយទីភ្នាក់ងារផ្សេងៗ ដូចជា អង្គការ AFSC និង កម្មវិធីប្រាសាក់ ជាដើម ។ ឧ. នៅស្ទឹងជ្រៃបាក់ ខេត្តកំពង់ឆ្នាំង ពុំមានការសិក្សាលំអិតពីដែនរងទឹកភ្លៀងនានា នៅមុនពេលរចនារៀបចំប្រព័ន្ធស្រោចស្រពនីមួយៗទេ ពីព្រោះនៅទសវត្សរ៍១៩៨០ និង១៩៩០ ខ្មែរក្រហមនៅកាន់កាប់ទឹកដីជាច្រើននៅឡើយ ហើយមានការប្រយុទ្ធគ្នាជារឿយៗនៅតាមកន្លែងទាំងនោះ ។ ក្នុងករណីភាគច្រើន ប្រព័ន្ធស្រោចស្រពបានកសាងឡើងជាសំខាន់ ដើម្បីផ្គត់ផ្គង់ទឹកបន្ថែមជាបន្ទាន់ដល់ស្រូវវស្សា និងធ្វើការគ្រប់គ្រងទឹកជំនន់ ។ ដោយសារហេតុផលខាងសន្តិសុខ ប្រព័ន្ធទាំងនោះត្រូវបានកសាងនៅតំបន់ខ្សែទឹកខាងក្រោមនៃដែនរងទឹកភ្លៀង នៅត្រង់កន្លែងមានសុវត្ថិភាព ។ បន្ទាប់ពីមានសន្តិសុខ និងស្ថិរភាពក្នុងប្រទេស សកម្មភាពអភិវឌ្ឍន៍ និងប្រព័ន្ធស្រោចស្រព ក៏កើនឡើងដែរ ។ នៅតំបន់ខ្សែទឹកខាងលើ មានការកសាងប្រព័ន្ធស្រោចស្រពថែមទៀត ដែលជួយឱ្យកសិកររស់នៅទីនោះអាចយកទឹកមកប្រើប្រាស់បាន ។ ប៉ុន្តែទំនប់ទឹកនៅតំបន់ខ្សែទឹកខាងលើ បានកាត់បន្ថយបរិមាណទឹកសំរាប់អ្នកនៅខ្សែទឹកខាងក្រោម ហើយនៅពេលមានទំនប់កាន់តែច្រើននៅតំបន់ខ្សែទឹកខាងលើ បរិមាណទឹកក៏កាន់តែថយចុះសំរាប់ប្រជាជននៅខ្សែទឹកខាងក្រោម ។

ទន្ទឹមនឹងការប្រកួតប្រជែងរវាងប្រព័ន្ធស្រោចស្រពនីមួយៗ ដើម្បីយកទឹកបន្ថែម កំណើនការធ្វើស្រែប្រាំងដោយសារមានទឹកស្រោចស្រព បាននាំឱ្យមានការប្រកួតប្រជែងគ្នា នៅក្នុងប្រព័ន្ធស្រោចស្រពតែមួយ និងរវាងប្រព័ន្ធនានា ។ ជាគោលការណ៍ គឺមានផ្ទៃដីមួយចំនួនច្បាស់លាស់ដែលមានការព្រមព្រៀងគ្នាថា អាចទទួលបានទឹកពីប្រព័ន្ធស្រោចស្រពនៅរដូវប្រាំង ។ ប៉ុន្តែ ក្នុងការអនុវត្តន៍ជាក់ស្ដែង គេពិបាកនឹងកំណត់បរិមាណដាំដុះនៅក្នុងតំបន់នោះណាស់ ។

បញ្ហាប្រឈមមួយទៀតទាក់ទិននឹងការបែងចែកទឹក រវាងប្រព័ន្ធស្រោចស្រពនានា គឺការសំរបសំរួល និងកិច្ចសហការមិនល្អរវាង FWUC ។ ផ្លូវទឹកឆ្លងកាត់ខេត្ត ស្រុក ឃុំ និងភូមិខុសៗគ្នា ដែលមានសហគមន៍កសិករប្រើប្រាស់ទឹកខុសៗគ្នា ។ ជារឿយៗ សហគមន៍កសិករប្រើប្រាស់ទឹកមិនអាចផ្លាស់ប្ដូរព័ត៌មានពីអ្វី ដែលកើតមាននៅតំបន់នីមួយៗទេ ហើយពួកគេធ្វើសេចក្ដីសំរេចចិត្តដោយឯករាជ្យ គ្មានការចូលរួមពីសហគមន៍កសិករប្រើប្រាស់ទឹកឯទៀតឡើយ ។ ជារឿយៗការសំរេចចិត្តរបស់សហគមន៍កសិករប្រើប្រាស់ទឹកនៅខ្សែទឹកខាងលើ វាជះឥទ្ធិពលយ៉ាងខ្លាំងដល់សហគមន៍កសិករប្រើប្រាស់ទឹកនៅខ្សែទឹកខាងក្រោម ។ ឧ. ពេលខ្លះ សហគមន៍កសិករប្រើប្រាស់ទឹកនៅខ្សែទឹកខាងលើបានទប់យកទឹកទាំងអស់ទៅប្រើប្រាស់ ធ្វើឱ្យអ្នកនៅខ្សែទឹកខាងក្រោម ខ្វះទឹកនៅចំពេលដែលស្រូវត្រូវការទឹកខ្លាំងបំផុត ហើយពេលខ្លះទៀតអ្នកខាងលើបានបើកបញ្ចេញទឹកទាំងអស់ធ្វើឱ្យលិចលង់ តំបន់ខ្សែទឹកខាងក្រោមនៅចំពេលច្រូតកាត់តែម្ដង ។ ដំណើរការ ប្រព័ន្ធស្រោចស្រពទឹកនីមួយៗ វាជាប់ទាក់ទងគ្នាចុះឡើង ។ ហេតុនេះ កិច្ចសហការជិតស្និទ្ធរវាងប្រព័ន្ធនានាក្នុងដែនរងទឹកភ្លៀងតែមួយ គឺសំខាន់ខ្លាំងណាស់ ។ សហគមន៍កសិករប្រើប្រាស់ទឹក មានការទទួលខុសត្រូវលើប្រព័ន្ធនៅតាមតំបន់ខុសៗគ្នាក៏ពិតមែន ប៉ុន្តែត្រូវមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាប្រចាំ ដើម្បីបង្កើតជាផែនការមេសំរាប់ការប្រើប្រាស់ទឹក ។

*ការចូលរួម*

យោងតាមឯកសារជាច្រើន ជោគជ័យនៃការគ្រប់គ្រងទឹកនៅមូលដ្ឋាន វាអាស្រ័យលើការចូលរួមរបស់ប្រជាជន ដែលអាចផ្ដល់ជាចំណេះដឹងខាងផ្នែកបច្ចេកទេសជាក់ស្ដែង ហើយសំខាន់ជាងនេះ គឺពួកគេមានអារម្មណ៍ក្លាយជាម្ចាស់ ។ ប៉ុន្តែការព្យាយាមឱ្យពួកគេចូលរួមក្នុងការគ្រប់គ្រង រឺប្រើប្រាស់ទឹកឱ្យមានប្រយោជន៍ វាក៏ពិបាកដូចគ្នានឹងការបែងចែកទឹកនៅពេលក្រទឹកដូច្នោះដែរ ។

FWUC បានជួបបញ្ហាធំក្នុងការកៀងគរឱ្យប្រជាជនមកចូលរួម ។ នៅតំបន់ខ្លះ ក្រោយពេលប្រព័ន្ធស្រោចស្រពបានកសាងនិងស្ដាររួចរាល់ហើយ គេមានទឹកច្រើនណាស់ ប៉ុន្តែកសិករមិនបានប្រើប្រាស់វាជាប្រយោជន៍ទេ ។ នៅតំបន់ខ្លះ FWUC បានព្យាយាមឱ្យប្រជាជនមូលដ្ឋានចូលរួម ប៉ុន្តែត្រូវប្រឈមមុខនឹងប្រពៃណីជាយូរលង់របស់កសិករ ។ តាមទំលាប់ កសិករធ្វើ

ស្រែវស្សាតាមសំរួលខ្លាំងណាស់ ។ FWUC នៅខេត្តកំពង់ធំបានលើកថា ក្នុងការធ្វើស្រែវស្សា កសិករគ្រាន់តែភ្ជួររាស់ដី និងសាបព្រួស ហើយគ្មានធ្វើអ្វីទៀតទេ រហូតដល់ពេលច្រូតកាត់ ។ ប៉ុន្តែស្រែប្រាំងទាមទារឱ្យកសិករចំនាយពេលច្រើនណាស់នៅឯស្រែ ដើម្បីត្រួតពិនិត្យទឹក ការពារកុំឱ្យសត្វចូលស៊ីស្រូវ ពីព្រោះជាទំលាប់ពួកគេព្រលែងពួកវានៅរដូវប្រាំង ។ ម្យ៉ាងទៀត កសិករត្រូវចំណាយច្រើនជាងមុន ដោយពួកគេត្រូវបង់កំរៃប្រើប្រាស់ទឹក (ទឹកនៅរដូវវស្សា គ្មានបង់ប្រាក់អ្វីទេ) ហើយស្រូវប្រាំងក៏ត្រូវការជីច្រើនជាងដែរ ។

ថ្វីបើមានការងារលើសមុន និងត្រូវចំណាយច្រើន ប៉ុន្តែមិនច្បាស់ថាបានផលនោះទេ ពីព្រោះកសិករអាចជួបនឹងគ្រោះសត្វចង្រៃបំផ្លាញដំណាំ ។ នៅរដូវវស្សា ដីស្ទើរតែទាំងអស់មានការដាំដុះ ដូច្នេះការខូចខាត ដោយសារសត្វចង្រៃ វាមានតិចជាង ។ ស្រូវប្រាំងគ្របដណ្តប់ផ្ទៃដីតូចជាង ដូច្នេះសត្វចង្រៃអាចបំផ្លិចបំផ្លាញធ្ងន់ជាង ពីព្រោះសត្វចង្រៃមានច្រើនជាងក្នុងដីស្រែមួយហិកតាៗ ។ មន្ត្រីផ្សព្វផ្សាយកសិកម្មនៅខេត្តពោធិ៍សាត់ បានពោលថា "ធ្វើស្រែប្រាំង គឺដូចជាបើកភោជនីយដ្ឋានបំរើសត្វកណ្តុរអញ្ចឹង" ។

នៅតំបន់ខ្លះ ដូចជាខេត្តពោធិ៍សាត់ និង សៀមរាប កសិករមិនប្រើប្រាស់ប្រព័ន្ធស្រោចស្រពទេ ដោយសារភាពក្រីក្រខ្លាំងពេក ។ កសិករមួយចំនួនមិនអាចទទួលផលពីប្រព័ន្ធនេះបាន ពីព្រោះគាត់មិនធ្វើស្រូវប្រាំង ហើយបែរជាទៅធ្វើពលករនៅឯទីក្រុង រកអុស រឺជីកយកថ្មម៉ាប ដែលជាការងារអាចរកប្រាក់បានភ្លាមៗ ។ គេអាចសង្កេតឃើញពីផលប៉ះពាល់នៃភាពក្រីក្រ តាមរយៈអ្នកក្រលក់ដីក្នុងតំលៃខ្ពស់ ទៅទិញដីមួយឡូតិ៍ផ្សេងទៀតដែលថោកជាង ប៉ុន្តែនៅឆ្ងាយពីប្រព័ន្ធស្រោចស្រព ។

ទោះបីដោយសារទំនៀមទំលាប់ រឺភាពក្រីក្រតោកយ៉ាកក្តី ប៉ុន្តែរឿងដែលប្រជាជនមិនប្រើប្រាស់ប្រព័ន្ធស្រោចស្រព រឺបង់ថ្លៃទឹក បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការងារជាទូទៅ និងជោគជ័យនៃ FWUC ។ FWUC ពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់វិភាគទានរបស់សមាជិក ។ មាត្រា២៤ នៃច្បាប់ FWUC តំរូវឱ្យកសិករដែលទទួលផលពីប្រព័ន្ធស្រែចស្រព បង់ថ្លៃប្រើប្រាស់ទឹក ។ ប៉ុន្តែជាប្រវត្តិសាស្ត្រ កសិករកម្ពុជាធ្វើស្រែពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង និងមិនដែលបង់ថ្លៃទឹកទេ ដូច្នេះគំនិតចង់ឱ្យកសិករបង់ថ្លៃប្រើប្រាស់ទឹក គឺជាបញ្ហារសើប ហើយពួកអ្នកនយោបាយបានធ្វើឱ្យវាកាន់តែធ្ងន់ធ្ងរថែម ។ អ្នកដឹកនាំគណៈបក្សនៅមូលដ្ឋាន បានប្រើប្រាស់ប្រព័ន្ធស្រោចស្រពជាឧបករណ៍ឃោសនាឱ្យគណៈបក្ស ដោយប្រាប់ប្រជាជនថា មិនបាច់បង់ថ្លៃអ្វីទេ ពីព្រោះរដ្ឋត្រូវកសាងទំនប់ទឹកសំរាប់ឱ្យប្រជាជនប្រើប្រាស់ ។ ទិដ្ឋភាពខាងនយោបាយមួយទៀត គឺមុនពេលបោះឆ្នោត គណៈបក្សនយោបាយសុំឱ្យប្រជាជនបោះឆ្នោតឱ្យខ្លួនដោយសន្យាថាលែងយកថ្លៃប្រើប្រាស់ទឹក ។ តើការប្រមូលទារថ្លៃទឹកជះឥទ្ធិពលយ៉ាងណាចំពោះការបំពេញតួនាទី និងចីរភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹក?

## *ប្រតិបត្តិការ*

កំហុសបច្ចេកទេសក្នុងការរចនារៀបចំទំនប់ទឹក វាចោទបញ្ហាយ៉ាងធំដល់ការថែទាំជួសជុល និងប្រតិបត្តិការរបស់ FWUC ។ ឧ. នៅទំនប់ត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ មានទ្វារទឹកធំដែលប្រើផ្ទាំងឈើបិទបើកទឹក ។ កសិករអាចកែតំរូវលំហូរទឹកចូលស្រែបាន ដោយដាក់ថែម រឺដកចេញផ្ទាំងឈើដោយដៃ ។ ប៉ុន្តែ នៅពេលជួសជុលលើកក្រោយនេះ គេបានផ្លាស់ប្តូរទ្វារ ទៅជាទ្វារស្វ័យប្រវត្តិវិញ ។ ទ្វារនេះអាចកែតំរូវលំហូរទឹកដោយខ្លួនឯង ដើម្បីកាត់បន្ថយការងាររបស់ FWUC ប៉ុន្តែវាដំណើរការមិនត្រឹមត្រូវទេ ។ បើតាម FWUC នៅមូលដ្ឋាន ទ្វារនឹងបើកនៅពេលមានទឹកច្រើនក្នុងទំនប់ ប៉ុន្តែវាមិនអាចបិទដើម្បីទប់ទឹកទុក ទៅតាមកំរិតដែលគេចង់បាននោះទេ ។ ទ្វារថ្មីនេះច្រើនបើកបង្ហូរទឹកចេញអស់រលីង ធ្វើឱ្យជន់លិចដីស្រែនៅខ្សែទឹកខាងក្រោម ។

លក្ខខណ្ឌរូបវន្តបានកាត់បន្ថយលទ្ធភាពរបស់ FWUC ក្នុងការផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់ដល់កសិករ ។ ប្រព័ន្ធស្រោចស្រពភាគច្រើន ពុំមានលក្ខណៈពេញលេញទេ ។ ឧ. ទំនប់ត្រពាំងថ្ម មានតែអាងស្តុកទឹកប៉ុណ្ណោះ រីឯប្រឡាយមេវាខូចខាតយ៉ាងខ្លាំង និងគ្មានកូនប្រឡាយចែកចាយទឹកទេ ។ ម្យ៉ាងទៀត ប្រឡាយមេដែលនាំទឹកទៅប្រព័ន្ធស្រោចស្រពស្រះរាំង នៅបន្ទាយមានជ័យ ក៏ខូចខាតខ្លាំងដែរ ។ យោងតាមប្រធាន FWUC នៅទីនោះ ប្រឡាយមេ បានខូចនៅ ១៣កន្លែងខុសៗគ្នា ដោយសារទឹកជំនន់កាលពីមួយឆ្នាំមុន ។ ស្ថានភាពប្រឡាយមិនសូវល្អនេះ នាំឱ្យ FWUC មិនអាចបំពេញតំរូវការកសិករបានទាន់ពេល ។ កសិករម្នាក់លើកថា "កាលពីឆ្នាំមុន ខ្ញុំសុំទឹកពី FWUC នៅខែវិច្ឆិកា ហើយពួកគេបានទៅចរចាជាមួយឃុំនៅខ្សែទឹកខាងលើ ដើម្បីឱ្យគេបើកទឹកបង្ហូរមក ។ ក្នុងពេលជាមួយគ្នា ខ្ញុំក៏ចាប់ផ្តើមភ្ជួររាស់ដាំដុះ និងរង់ចាំទឹក ។ យើងចាំហើយចាំទៀត ។ មួយខែក្រោយពេលខ្ញុំសាប ទឹកក៏ហូរមកដល់ ប៉ុន្តែវាយឺតពេលទៅហើយ ពីព្រោះស្រូវបានងាប់អស់រលីង ។

ធនធានតិច ក៏ជាឧបសគ្គក្នុងការគ្រប់គ្រងទឹកដែរ ។ ប្រភពចំណូលរំពឹងទុករបស់ FWUC គឺថវិកាបានមកពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ថ្លៃទឹកស្រោចស្រព និងសកម្មភាពអាជីវកម្មរបស់ FWUC ផ្ទាល់ ។ ប៉ុន្តែចំណូលពីរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល់ និងសកម្មភាពអាជីវកម្ម មានតិចតួចបំផុត រឺគ្មានសោះ ហើយ FWUC ស្ទើរតែមិនអាចប្រមូលថ្លៃប្រើប្រាស់ទឹកបានទៀត ។ ដោយសារចំណូលតិចតួច ដូច្នេះ FWUC មិនបានបំពេញតួនាទីខ្លួនប្រកបដោយប្រសិទ្ធភាពទេ ពីព្រោះគណៈកម្មាធិការទទួលបានកំរៃតែ ១០០០០រៀល-២០០០០រៀលប៉ុណ្ណោះ ក្នុង១ឆ្នាំ គឺមិនគ្រប់ទិញសាំងធ្វើដំណើរមួយជើងទៅចរចារជាមួយឃុំនៅខ្សែទឹកខាងលើផង ហើយពួកគេត្រូវប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនតែរាល់ៗលើក ។

ម្យ៉ាងទៀត កសិករមិនបានជួយសំរួលដល់ការងារគណៈកម្មាធិការទេ ។ យោងតាមការបកស្រាយខាងលើ បរិមាណទឹកនៅក្នុងប្រព័ន្ធស្រោចស្រព ទោះតិចក្តី ច្រើនក្តី គឺកំណត់ដោយអ្នកនៅខ្សែទឹកខាងលើ ប៉ុន្តែកសិករបន្ទោសតែ FWUC ក្នុងមូលដ្ឋានខ្លួនប៉ុណ្ណោះ ។ សមាជិកគណៈកម្មាធិការម្នាក់ប្រាប់ថា "នៅក្នុងមួយរដូវច្រូតកាត់ យើងត្រូវគេជេរបីដង ។ លើកទី១ នៅពេលខ្វះទឹកនាំឱ្យផលដំណាំខូច ។ លើកទី២ នៅពេលទឹកជន់ពីខ្សែទឹកខាងលើ ហើយបំផ្លាញដំណាំ និងលើកទី៣ នៅពេលយើងទៅប្រមូលថ្លៃប្រើប្រាស់ទឹក" ។

បញ្ហាខាងលើ បានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ចីរភាពរបស់គណៈកម្មាធិការ FWUC ដូចក្នុងសំដីរបស់សមាជិកគណៈកម្មាធិការម្នាក់ នៅខេត្តកំពង់ឆ្នាំងដែលថា "ប្រហែលជាយើងគួរឈប់ហើយ ពីព្រោះយើងមិនបានទទួលប្រាក់កំរៃសំរាប់សេវារបស់យើងទេ គឺមានតែគេបន្ទោស" ។ ឧ. FWUC នៅទំនប់ថ្នល់ដាច់ ខេត្តបន្ទាយមានជ័យ ធ្លាប់មានសមាជិកគណៈកម្មាធិការ ៥នាក់ ប៉ុន្តែឥឡូវនៅសល់តែ ៣នាក់ទេ ។ រឿងនេះក៏កើតឡើងចំពោះ FWUC នៅទំនប់កំពឹងពួយ (បាត់ដំបង) ទំនប់កំបាំង (ពោធិ៍សាត់) ទំនប់មេទឹក (ពោធិ៍សាត់) ទំនប់តាំងក្រសាំង (កំពង់ឆ្នាំង) ដែរ ។ ប្រធាន FWUC នៅតាំងក្រសាំង ពោលថា "កាលពីមុន សមាជិកគណៈកម្មាធិការសប្បាយរីករាយចំពោះការគ្រប់គ្រងប្រព័ន្ធស្រោចស្រព ប៉ុន្តែឥឡូវនេះ ម្នាក់ៗបាក់ទឹកចិត្ត ពីព្រោះមិនបានទទួលកំរៃអ្វីសោះ" ។

*ការថែទាំជួសជុល*

FWUC ក៏ខ្វះធនធានសំរាប់ថែទាំជួសជុលប្រព័ន្ធស្រោចស្រពដែរ ។ ប្រព័ន្ធងាយខូចខាត ដោយសារការហូរច្រោះ ទឹកជំនន់ សត្វពាហនៈបំផ្លាញ និងចោរលួច ដូចជា របាដែក និងទ្វារឈើ ជាដើម ។ ជាញឹកញាយ ចំណាយជួសជុលខ្ពស់ជាងថវិការបស់ FWUC ដែលបានចំណូលពីថ្លៃប្រើប្រាស់ទឹកដែលពិបាកប្រមូលបានជាខ្លាំង រឺប្រមូលមិនបានតែម្តង ។

ការពិបាកបំផុត គឺជួនកាល សហគមន៍កសិករប្រើប្រាស់ទឹកត្រូវទៅជួសជុលប្រព័ន្ធស្រោចស្រពនៅតំបន់គេផ្សេង ។ ឧ. សហគមន៍កសិករប្រើប្រាស់ទឹកនៅស្រះរាំងត្រូវ ទទួលបន្ទុកថែទាំជួលជុល ប្រព័ន្ធនៅឯខ្សែទឹកខាងលើនៅពោធិ៍ពីរដើម (បន្ទាយមានជ័យ) ។ ប្រឡាយមេដែលនាំទឹកទៅស្រះរាំងត្រូវឆ្លងកាត់ពោធិ៍ពីរដើម ហើយវាបានខូចខាតជាច្រើនកន្លែង ប៉ុន្តែកសិករនៅទីនោះមិនធ្វើស្រែប្រាំង ដូច្នេះគេមិនចាប់អារម្មណ៍ជួសជុលប្រឡាយមេទេ ដោយទុកឱ្យសហគមន៍កសិករប្រើប្រាស់ទឹកនៅស្រះរាំង ទទួលខុសត្រូវលើរឿងនេះ ។

សហគមន៍កសិករប្រើប្រាស់ទឹកមួយចំនួន បានព្យាយាមដាក់បញ្ចូលការកសាងប្រព័ន្ធស្រោចស្រព ទៅក្នុងផែនការរបស់ក្រុមប្រឹក្សាឃុំ ប៉ុន្តែបទពិសោធន៍ជាក់ស្តែងបង្ហាញថា លទ្ធភាពធ្វើដូច្នេះបានវាមានកំរិតតិចតួចណាស់ ។ សមាជិកម្នាក់នៃសហគមន៍កសិករប្រើប្រាស់ទឹកនៅខេត្តកំពង់ឆ្នាំងបញ្ជាក់ថា "យើងបានព្យាយាមបញ្ចូលប្រព័ន្ធស្រោចស្រពនេះ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំដែរ ប៉ុន្តែប្រព័ន្ធនេះមិនអាចយកឈ្នះទៅលើផ្លូវថ្នល់បានទេ" ។

*ទំនាស់ និងការដោះស្រាយ*

ឯកសារស្តីពីការដោះស្រាយទំនាស់ក្នុងការគ្រប់គ្រងទឹកនៅកម្ពុជា មានតិចតួចណាស់ ប៉ុន្តែបទពិសោធន៍អន្តរជាតិ បង្ហាញថា ទំនាស់រវាងអ្នកប្រើប្រាស់ទឹកបានកើនឡើង ដោយសារការធ្វើវិមជ្ឈការ (UNDP 2006) ។ ទំនាស់នៅមូលដ្ឋានភាគច្រើន ពាក់ព័ន្ធនឹងការបែងចែកទឹករវាងប្រព័ន្ធស្រោចស្រពនានា ហើយវាតែងកើតឡើងពីចុងខែកុម្ភៈ ដល់ដើមខែមីនា នៅពេលកសិករត្រូវការទឹកធ្វើស្រែប្រាំង ។ ឧ. នៅឆ្នាំ២០០៦ ស្រូវប្រាំងនៅត្រពាំងត្របែក ខេត្តកំពង់ឆ្នាំង បានដុះលូតលាស់ល្អណាស់ រហូតដល់ពេលខ្វះទឹកនៅចុងខែកុម្ភៈ ។ ដោយមានព័ត៌មានតិចតួចពីរបបលំហូរទឹក កសិករក្នុងតំបន់នោះយល់ថា កង្វះទឹកបណ្តាលមកពី FWUC និងកសិករនៅខ្សែទឹកខាងលើ មានចិត្តច្រណែននឹងជីវភាពធូរធារដោយសារផលស្រូវប្រាំងរបស់ពួកគេ ។ កសិករនៅខ្សែទឹកខាងក្រោមនិយាយថា "ដូច្នេះពួកគេក៏បិទទឹកទាំងអស់ មិនឱ្យហូរចុះមកតំបន់ខ្សែទឹកខាងក្រោម" ។

ទោះយ៉ាងនេះក្តី សព្វថ្ងៃមិនទាន់មានក្របខ័ណ្ឌច្បាប់ច្បាស់លាស់ទេ (Sakhon and Lyda 1996) សំរាប់ដោះស្រាយទំនាស់ ហើយក្នុងករណីភាគច្រើន កសិករ និងសហគមន៍កសិករប្រើប្រាស់ទឹកបានប្រើប្រាស់វិធីសាស្ត្រផ្ទាល់ខ្លួន ដើម្បីដោះស្រាយបញ្ហា ។ ឧ. នៅពេលឃើញដំណាំស្រូវអាចខូចខាត កសិករបានរំលុយឱ្យសហគមន៍កសិករប្រើប្រាស់ទឹក ធ្វើដំណើរទៅតាំងក្រសាំងដើម្បីចរចាឱ្យគេបើកទឹក ។ តាមធម្មតា ការចរចាធ្វើឡើងជាលក្ខណៈក្រៅផ្លូវការប៉ុណ្ណោះ ។ បើសហគមន៍កសិករប្រើប្រាស់ទឹកត្រូវការទឹក ពួកគេយកម្ហូបអាហារ និងស្រា ទៅជាមួយដើម្បីធ្វើការចរចាជាមួយនឹងភាគីម្ខាងទៀត ។

ការបើកទឹកបង្ហូរពីតំបន់ខ្សែទឹកខាងលើ ជារឿយៗមិនប្រាកដថាមានទឹកមកដល់ប្រព័ន្ធស្រោចស្រពនៅខ្សែទឹកខាងក្រោមទេ ។ ប្រជាជនតែងគិតថា នៅពេលទឹកហូរមកដល់តំបន់ពួកគេ វាជារបស់ពួកគេ ដូច្នេះ ពួកគេមានសិទ្ធិធ្វើអ្វីក៏បានតាមចិត្តចង់ ។ នៅខេត្តកំពង់ធំ កំពង់ឆ្នាំង និង បន្ទាយមានជ័យ កសិករបានកសាងទំនប់បណ្តោះអាសន្នបង្វែរទឹកចូលស្រែរបស់ខ្លួន ធ្វើឱ្យរអាក់រអួលដល់របៀបរបបអភិបាលកិច្ចធនធានទឹក ។ ប៉ុន្តែ FWUC មិនអាចបញ្ជាឱ្យពួកគេ យកទំនប់ចេញបានទេ ។

## ៣. សេចក្តីសន្និដ្ឋាន

បញ្ហាដែលសហគមន៍កសិករប្រើប្រាស់ទឹកកំពុងប្រឈមមុខក្នុងការគ្រប់គ្រងទឹក បានកកើតឡើងតាំងពីដំណាក់កាលរចនារៀបចំប្រព័ន្ធស្រោចស្រព ហើយវាបំផុសសំណួរថា តើការគ្រប់គ្រង និងអភិបាលកិច្ចប្រព័ន្ធស្រោចស្រពអាចដោះស្រាយតាំងពីដំបូងៗបានរឺទេ ។ ស្របគ្នានេះដែរ ក៏គួរចោទសួរពីបញ្ហាជាទូទៅទាក់ទងនឹងសេដ្ឋកិច្ចនយោបាយនៃប្រព័ន្ធស្រោចស្រពដែរ ។ តើហេតុអ្វីបានជាគេកសាងគំរោងនៅទីតាំងសព្វថ្ងៃនេះ? ហេតុអ្វីកសិករមិនគោរពភាពពេញច្បាប់នៃសហគមន៍កសិករប្រើប្រាស់ទឹក? តើសហគមន៍កសិករប្រើប្រាស់ទឹក ពិតជាស្ថាប័នគ្រប់គ្រងធនធានទឹកនៅមូលដ្ឋានដែលមានច្បាប់ទ្រទ្រង់ត្រឹមត្រូវ រឺក៏គ្រាន់តែជាស្ថាប័នសាកល្បងដំបូងមួយប៉ុណ្ណោះ? តើហេតុអ្វីបានជាខ្វះកិច្ចសហការ និងសហប្រតិបត្តិការរវាងសហគមន៍កសិករប្រើប្រាស់ទឹកនានា ហើយតើត្រូវធ្វើយ៉ាងទើបមានកិច្ចសហការគ្នា? នៅពេលបញ្ហាទាំងនេះ ដោះស្រាយបានរួចរាល់ហើយ ទើបអាចនិយាយបានពី ការគ្រប់គ្រងទឹកប្រកបដោយប្រសិទ្ធភាពដោយសហគមន៍កសិករប្រើប្រាស់ទឹក ។

## ឯកសារយោង


International Conference on Water and the Environment (ICWE) (1992), "The Dublin Statement on Water and Sustainable Development", httpp://www.gdrc.org/uem/water/dublin-statement.html

McDonald, A.T. & D. Kay (1988), *Water resources—issues and strategies* (London: Longman)

Ministry of Water Resources and Meteorology (2000), "Circular No. 1 on the Implementation policy for sustainable irrigation systems" (Phnom Penh)

Moote, M.A., M. P. McClaran & Donna K. Chickering (1997), "Theory in practice: applying participatory democracy theory to public land planning", *Environmental Management,* 21: 6

Ojendal, J. (2000). "Sharing the good: Modes of managing water resources in the lower Mekong River Basin", PhD dissertation (Goteborg University)

Royal Government of Cambodia (2006), *National Development Strategic Plan 2006–2010* (Phnom Penh)

Sakhon, V. & P. Lyda (1996), "National institution for integrated water resource management", *CNMC and UNDDSMS* (Phnom Penh)

Schumacher, E. F. (1973), *Small is beautiful: A study of economics as if people mattered* (London: Bland and Briggs)

UNDP (2006), *Human development report: Beyond scarcity: Power, poverty and the global water crisis* (UNDP)

# ពាណិជ្ជកម្មកសិកម្មនៅមហាអនុតំបន់មេគង្គៈ ការប្រមើលមើលពីការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា

*បណ្ឌិត ធន់ វឌ្ឍនា បណ្ឌិត សុខ ស៊ីណា និងលោកស្រី ឆាយ ពិដោរ ពិភាក្សាពីស្ថានភាពបច្ចុប្បន្ននៃពាណិជ្ជកម្មក្នុងតំបន់លើទំនិញកសិកម្ម និងចំណងទាក់ទងជាមួយការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា និងពិនិត្យពីការវិវត្តន៍ទៅអនាគតនៃពាណិជ្ជកម្មកសិកម្មក្នុងតំបន់ និងផ្តល់អនុសាសន៍ខាងគោលនយោបាយសំដៅជំរុញពាណិជ្ជកម្មកសិកម្មនៅ GMS ។**

## ប្រវត្តិខាងសេដ្ឋកិច្ច_សង្គមកិច្ចនៃបណ្តាប្រទេស GMS

មហាអនុតំបន់មេគង្គ (GMS) មានផ្ទៃក្រឡាសរុបប្រហែល ២,៣លានគ.ម$^{២}$ ប្រជាជន ២៦២លាននាក់ និងប្រទេសសមាជិកចំនួន ៦ គឺ កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម និង ខេត្តយូណាន់ នៃប្រទេសចិន ។ បណ្តាប្រទេសសមាជិកមានទន្លេរួមគ្នាមួយគឺ ទន្លេមេគង្គ ដែលមានប្រវែង ៤.២០០គ.ម និងជាទន្លេវែងជាងគេក្នុងលំដាប់ទីដប់ នៅលើពិភពលោក ។ GMS សំបូរធនធានធម្មជាតិ មានរ៉ែច្រើនមុខ មានសក្តានុពលខាងវារីអគ្គិសនី ធនធានត្រី និងដីជីជាតិល្អ ។

ចំណែកនៃកសិកម្មនៅក្នុងសេដ្ឋកិច្ចមានពី ១១% នៅថៃ រហូតដល់ជិត ៥០% នៅមីយ៉ាន់ម៉ា (តារាង១) ។ ថ្វីបើកសិកម្មនៅមានចំណែកធំក្នុងផសស ប៉ុន្តែប្រទេសនីមួយៗបានប្រឹងប្រែងកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ចរបស់ខ្លួន ទៅខាងឧស្សាហកម្ម និងសេវាកម្មវិញ ។ លើកលែងតែប្រទេសថៃដែលមានសេដ្ឋកិច្ចទីផ្សារជាច្រើនទសវត្សរ៍មកហើយ ប្រទេស GMS ទាំង ៥ទៀតសុទ្ធតែជាអតីតសេដ្ឋកិច្ចមានផែនការប្រមូលផ្តុំ និងមានមធ្យោបាយផលិតកម្មជារបស់រដ្ឋ ហើយសព្វថ្ងៃកំពុងធ្វើអន្តរកាលទៅកាន់សេដ្ឋកិច្ចទីផ្សារ និងបើកចំហសេដ្ឋកិច្ចឱ្យបរទេសមកបណ្តាក់ទុន ។ ប៉ុន្តែនៅ មីយ៉ាន់ម៉ា ដំណើរការនេះយឺតយ៉ាវ ដោយសារហេតុផលខាងនយោបាយ ។

ដោយមានកំលាំងពលកម្មច្រើន និងប្រាក់ចំណូលក្នុងមនុស្សម្នាក់កំពុងកើនឡើង បណ្តាប្រទេស GMS មានមូលដ្ឋានផលិតកម្មមានលក្ខណៈទាក់ទាញល្អ និងជាទីផ្សារសក្តានុពល ។ ក្រុមហ៊ុននានានៅអាស៊ីខាងកើត កំពុងផ្ទេរកាន់តែច្រើនឡើងនូវផលិតកម្មប្រើពលកម្មច្រើន មកដំណើរការនៅក្នុង GMS វិញ ដើម្បីអាចប្រើប្រាស់កំរិតបៀវត្សរ៍មានលក្ខណៈប្រកួតប្រជែង នឹងកំលាំងពលកម្មដែលនៅសល់ច្រើន និងកាន់តែមានជំនាញខ្ពស់ ។

ពាណិជ្ជកម្មអន្តរជាតិនៃ GMS ទាំងមូល មានឱនភាពបន្តិច ប៉ុន្តែសំរាប់ប្រទេសមិនមែនឥណ្ឌូចិនទាំងបី គឺមានអតិរេក ។ បណ្តាប្រទេស GMS នាំចេញផលិតផលជាច្រើនមុខ ប៉ុន្តែភាគច្រើនស្ថិតក្នុង ២-៣ ប្រភេទប៉ុណ្ណោះ ។ វាយនភ័ណ្ឌគឺជាទំនិញនាំចេញឃើញមានជាទូទៅនៅឥណ្ឌូចិន ហើយចំណែកភាគរយនៅក្នុងការនាំចេញសរុបមានតាំងពី ១៣,៣% នៅវៀតណាម រហូតដល់ ៧៦,៩% នៅកម្ពុជា ។ ដើម្បីបង្កើនពាណិជ្ជកម្ម បណ្តាប្រទេស GMS បានប្តេជ្ញាបើកចំហសេដ្ឋកិច្ច និងធ្វើកំណែទំរង់រចនាសម្ព័ន្ធស្របតាមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) និង កម្មវិធីប្រមូលផលដើមដៃ ។ លើកលែងតែមីយ៉ាន់ម៉ា និង ឡាវ ចេញ ប្រទេស GMS ទាំងអស់សុទ្ធតែជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

អត្ថបទនេះ ពិភាក្សារំរែកញែកពីស្ថានភាពបច្ចុប្បន្ននៃពាណិជ្ជកម្មក្នុងតំបន់លើទំនិញកសិកម្ម និងចំណងទាក់ទងជាមួយការអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា ។ អត្ថបទ ក៏ពិនិត្យពីការវិវត្តន៍ទៅអនាគតនៃពាណិជ្ជកម្មកសិកម្មក្នុងតំបន់ និងផ្តល់អនុសាសន៍ខាងគោលនយោបាយ សំដៅជំរុញពាណិជ្ជកម្មកសិកម្មនៅតំបន់ GMS ។ ការសិក្សានេះផ្តោតលើប្រទេសកម្ពុជាតែមួយ រីឯព័ត៌មានស្តីពីប្រទេស GMS ឯទៀត គឺសំរាប់ប្រៀបធៀបគ្នាតែប៉ុណ្ណោះ ។

## ពាណិជ្ជកម្ម និងការអភិវឌ្ឍន៍

*ប្រវត្តិសង្ខេប*

តួនាទីពាណិជ្ជកម្មអន្តរជាតិក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច បានទទួលការយកចិត្តទុកដាក់ពីសេដ្ឋវិទូ អ្នកកសាងគោលនយោបាយ អ្នកនយោបាយ និងក្រុមហ៊ុនអន្តរជាតិធំៗ ជាច្រើនសតវត្សរ៍មកហើយ ។ ថ្វីបើពាណិជ្ជកម្មនេះ បានកើតមានជាច្រើនរយឆ្នាំ ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធរបស់វានៅតែអន់ខ្សោយ ក្នុងមួយភាគធំនៃរយៈពេលនោះ ។ ទីផ្សាររូបិយវត្ថុ ទីផ្សារទំនិញ និងទីផ្សារឥណទាន បានរីកលូតលាស់ដើម្បីជួយសំរួលពាណិជ្ជកម្ម និងការពង្រីកទឹកដីអាណានិគម ក្នុងសតវត្សរ៍ទី១៦ និង ១៧ ។ នៅពេលនោះ ទ្រឹស្តីសេដ្ឋកិច្ចដែលគេហៅថា ពាណិជ្ជកម្មនិយម បានជំរុញការនាំចេញ ប៉ុន្តែបន្ទបង្អាក់ការនាំចូល ។ ដូច្នេះហើយក៏មានគោលនយោបាយពាណិជ្ជកម្មរឹតត្បិតច្រើនបែបច្រើនយ៉ាង ដូចជា ពន្ធនាំចូល អាជ្ញាប័ណ្ណ និង ឧបត្ថម្ភធនសំរាប់ការនាំចេញ ជាដើម ។

ក្នុងសម័យបដិវត្តន៍ឧស្សាហកម្មនៅចុងសតវត្សរ៍ទី១៨ គោលគំនិតបែបពាណិជ្ជកម្មនិយម កាន់តែមានគេជំទាស់ច្រើន ពីព្រោះវត្ថុធាតុដើមសំរាប់បង្កើនទំនិញនាំចេញ មិនអាចផ្គត់ផ្គង់គ្រប់គ្រាន់ ដោយផលិតកម្មក្នុងស្រុកបានទេ ដូច្នេះសាមីប្រទេសត្រូវតែបន្ធូរបន្ថយគោលនយោបាយពាណិជ្ជកម្មលើការនាំចូលវត្ថុធាតុដើម ។ នៅដើមសតវត្សរ៍ទី១៩ ចលនាធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចដ៏ខ្លាំងក្លាមួយបានកកើតឡើង តាមរយៈការលុបបំបាត់ជាឯកតោភាគីនូវកំហិតផ្សេងៗលើពាណិជ្ជកម្មនៅក្នុង ចក្រភពអង់គ្លេស (មហាអំណាចសេដ្ឋកិច្ចនាពេលនោះ) ដោយចាប់ផ្តើមតាមការលុបច្បាប់ដំណាំពោត (Corn Law) នៅឆ្នាំ១៨៤៦ ដែលបានបញ្ចប់កម្មវិធីទ្រទ្រង់ថ្លៃផលិតផលកសិកម្មដ៏ធំលើកទី១ ក្នុងពិភពលោក ។ បន្ទាប់មកអង់គ្លេសក៏ព្យាយាមធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មពិភពលោក ដោយទទួលបានជោគជ័យមួយចំនួន ។ ពាណិជ្ជកម្មពិភពលោក មានលក្ខណៈសេរីគួរសមរហូតដល់សង្គ្រាមលោកលើកទី១ ដោយមានគោលនយោបាយការពារផលិតផលក្នុងស្រុក តែលើមុខសញ្ញាខ្លះៗប៉ុណ្ណោះ (Norton and Alwang 1993) ។ ការរីកលូតលាស់ក្នុងការដឹកជញ្ជូន និងទូរគមនាគមន៍ ក៏បានជួយជំរុញដល់ពាណិជ្ជកម្មមួយកំរិតទៀត ។

សកម្មភាពអាជីវកម្មនានារួមទាំងកសិកម្មផង ដែលរីកដុះដាលក្នុងពេលសង្គ្រាម បានជួបឧបសគ្គនៃការធ្លាក់ចុះតំរូវការ និងថ្លៃទំនិញ ក្រោយចប់

---

* បណ្ឌិត ធន់ វឌ្ឍនា ជាប្រធានស្រាវជ្រាវផ្នែកកសិកម្ម អភិវឌ្ឍន៍ជនបទ និងភាពក្រីក្រ បណ្ឌិត សុខ ស៊ីណា ជាអ្នកស្រាវជ្រាវ និងលោកស្រី ឆាយ ពិដោរ ជាជំនួយការស្រាវជ្រាវនៃវិទ្យាស្ថាន CDRI ។

តារាង១ : ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចនៃបណ្តាប្រទេស GMS

| | កម្ពុជា | ឡាវ | មីយ៉ាន់ម៉ា | ថៃ | វៀតណាម | យូណាន់ | GMS |
|---|---|---|---|---|---|---|---|
| | 2006 | 2006 | 2006 | 2006 | 2006 | 2005 | 2005/6 |
| ផ្ទៃ (000 គម $^2$) | 181.04 | 236.80 | 678.50 | 514.00 | 329.56 | 394.10 | 2334.00 |
| ប្រជាជន (លាននាក់) | 14.10 | 6.52 | 47.37 | 65.23 | 84.16 | 44.50 | 261.89 |
| ផសស/ម្នាក់ (ដុល្លារ) | 419.00 | 425.18 | 202.64 | 3161.85 | 723.45 | 982.00 | 1251.85 |
| ផសស (លានដុល្លារ) | 5931.00 | 2773.00 | 9600.00 | 206,259.24 | 60,883.56 | 42,395.20 | 327,842.00 |
| កសិកម្ម (%) | 28.10 | 43.40 | 50.00 | 10.70 | 20.40 | 18.90 | 15.30 |
| ឧស្សាហកម្ម (%) | 28.70 | 30.60 | 15.00 | 44.60 | 41.50 | 41.76 | 42.38 |
| សេវាកម្ម (%) | 43.20 | 26.00 | 35.00 | 44.70 | 38.10 | 39.34 | 42.31 |
| នាំចេញ (លានដុល្លារ) | 3693.00 | 982.20 | 3560.00 | 130,583.42 | 39,826.00 | 2641.58 | 181,286.20 |
| នាំចូល (លានដុល្លារ) | 4749.00 | 1376.00 | 1980.00 | 128,606.12 | 44,891.00 | 2096.64 | 183,698.77 |

ប្រភព: ចងក្រង និងគណនាដោយអ្នកនិពន្ធ ដោយផ្អែកលើប្រភពជាច្រើន ២០០៧

សង្គ្រាម ។ ក្នុងទសវត្សរ៍១៩២០ និង ១៩៣០ រដ្ឋាភិបាលនានា បានព្យាយាមការពារអាជីវកម្មទាំងនេះ ដោយដាក់អនុវត្តគោលនយោបាយការពារផលិតផលក្នុងស្រុក ដែលពិភពលោកបានតស៊ូរហូតមកដល់សព្វថ្ងៃនេះ ដើម្បីលុបបំបាត់វាចេញវិញ ។ កិច្ចការពារផលិតផលក្នុងស្រុក អាចបង្កើតបន្ទុកចំណាយយ៉ាងច្រើន ធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៍មានការព្រួយបារម្ភ ពីព្រោះគេត្រូវបង្កើនការនាំចេញ ដើម្បីទទួលបានរូបិយប័ណ្ណសំរាប់សងបំណុល (Riddel et al. 2002) ។ គោលនយោបាយការពារផលិតផលក្នុងស្រុកមិនចេះចប់ អាចមើលឃើញយ៉ាងច្បាស់ក្នុងការបរាជ័យនៃកិច្ចចរចានៅអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ប្រទេសនីមួយៗអះអាងថា ផលិតផលបរទេសបានប្រកួតប្រជែងដោយអយុត្តិធម៌ ហើយថាផលិតផលរបស់គេផ្ទាល់វាសំខាន់បំផុតសំរាប់សេដ្ឋកិច្ចក្នុងស្រុក និងសុខមាលភាពកសិករ ។ ដូច្នេះរដ្ឋាភិបាលក្នុងឋានៈជាអ្នកការពារផលប្រយោជន៍សាធារណៈ ត្រូវតែផ្តល់កិច្ចគាំពារទល់នឹងទំនិញនាំចូល ទោះបីជាខ្លួនអះអាងថា គាំទ្រពាណិជ្ជកម្មសេរីក៏ដោយ ។

### *ផលប៉ះពាល់នៃពាណិជ្ជកម្ម*

ទាំងក្នុងប្រព័ន្ធផ្សព្វផ្សាយ និងមជ្ឈដ្ឋានអ្នកស្រាវជ្រាវ ពុំមានមតិឯកភាពគ្នាទេពីផលប៉ះពាល់នៃពាណិជ្ជកម្មសេរី ។ ជារឿយៗ ការពិភាក្សាពីពាណិជ្ជកម្មនាំឱ្យមានជំហរពីរផ្ទុយគ្នាគឺ ទី១-ទំនិញនាំចេញនានាជាពិសេសមកពីប្រទេសមានកំរិតអភិវឌ្ឍន៍ខ្ពស់ជាង វាបង្កបញ្ហាដល់ប្រទេសកំពុងអភិវឌ្ឍន៍ និង ទី២-ពាណិជ្ជកម្មបើកចំហវាចាំបាច់ណាស់សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ អ្នកគាំទ្រមតិអវិជ្ជមានលើពាណិជ្ជកម្មវែកញែកថា នៅពេលប្រទេសកំពុងអភិវឌ្ឍន៍បានធ្វើសមាហរណកម្មកាន់តែច្រើនទៅក្នុងសេដ្ឋកិច្ចពិភពលោក ពួកគេបើកចំហឱ្យមានការធ្វើអាជីវកម្ម កាន់តែច្រើននៅក្នុងប្រទេសខ្លួនពីសំណាក់ប្រទេសមានកំរិតអភិវឌ្ឍន៍ខ្ពស់ជាង និងពីអ្នកឋានៈខ្ពស់សំបូរធនធាន ។ អ្នកគាំទ្រមតិវិជ្ជមានលើពាណិជ្ជកម្មវែកញែកថា វាជួយសំរួលដល់ការអភិវឌ្ឍន៍ ពីព្រោះវានាំឱ្យមានការប្រើប្រាស់ធនធាននានាកាន់តែមានប្រសិទ្ធភាពខ្ពស់ ។ ប្រទេសជាតិអាចបានផលចំណេញ បើសិនគេនាំចេញទំនិញដែលគេអាចផលិតបានថោកជាងប្រទេសឯទៀត និងនាំចូលទំនិញណាដែលប្រទេសឯទៀតផលិតបានថោកជាង ។ អ្នកស្រាវជ្រាវមួយចំនួនវែកញែកថា ពាណិជ្ជកម្មសេរីនឹងផ្តល់ការរីកចំរើនដល់ទាំងប្រទេសនាំចូល និងប្រទេសនាំចេញ បើសិនប្រទេសទាំងពីរមានកំរិតអភិវឌ្ឍន៍សេដ្ឋកិច្ចស្មើគ្នា បើពុំនោះទេនឹងមានអ្នកឈ្នះ និងអ្នកចាញ់ ។ អ្នកចាញ់ភាគច្រើនជាប្រទេសនាំចូលដែលមានប្រសិទ្ធភាពទាបជាង និងសមត្ថភាពប្រកួតប្រជែងខ្សោយជាង ។ អ្នកឈ្នះ គឺជាប្រទេសនាំចេញដែលមានវិធីផលិតមានប្រសិទ្ធភាពខ្ពស់ ។

គំរូបែបបុរាណនៃពាណិជ្ជកម្មសេរីដែលផ្អែកលើការសន្មតថា មានប្រាក់ចំណូលទៀងទាត់ និងមានការប្រកួតប្រជែងល្អឥតខ្ចោះ វាលែងសូវសំខាន់ដូចកាលពីមុនទៀតហើយ ពីព្រោះមានករណីជាក់ស្តែងជាច្រើនបង្ហាញថាសព្វថ្ងៃ គឺប្រាក់ចំណូលកើនឡើងជាលំដាប់ (សេដ្ឋកិច្ចមាត្រដ្ឋាន) និងការប្រកួតប្រជែងមិនល្អឥតខ្ចោះ ដែលជាកត្តានាំឱ្យមានចរាចរទំនិញយ៉ាងច្រើននាពេលបច្ចុប្បន្ន ។ Paul Krugman (2003) អ្នកបង្កើតទ្រឹស្តីពាណិជ្ជកម្មថ្មី និងអ្នកស្រាវជ្រាវជាច្រើនទៀតបានអះអាងថា ពាណិជ្ជកម្មមិនមែនសុទ្ធតែជាលទ្ធផលនៃឧត្តមភាពប្រៀបធៀបនោះទេ ។ ផ្ទុយទៅវិញ វាអាចជាលទ្ធផលនៃប្រាក់ចំណូលកើនឡើងជាលំដាប់ រឺសេដ្ឋកិច្ចមាត្រដ្ឋាន ពោលគឺនិន្នាការថយចុះតំលៃឯកតា នៅពេលគេផលិតកាន់តែច្រើនឡើង ។

សេដ្ឋកិច្ចមាត្រដ្ឋាន បានជំរុញឱ្យប្រទេសនានាធ្វើឯកទេសនីយកម្មលើផលិតកម្ម និងពាណិជ្ជកម្ម ទោះបីធនធាន រឺបច្ចេកវិទ្យារបស់ខ្លួន គ្មានអ្វីខុសប្លែកពីគេក្តី ។ ក្នុងការពិតជាក់ស្តែង សេដ្ឋកិច្ចមាត្រដ្ឋានច្រើនជាលទ្ធផលនៃការប្រកួតប្រជែងមិនល្អឥតខ្ចោះ ជាជាងការប្រកួតប្រជែងល្អឥតខ្ចោះ ។ រដ្ឋាភិបាល មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតសេដ្ឋកិច្ចមាត្រដ្ឋានតាមរយៈការគាំទ្រដល់ការស្រាវជ្រាវ និងអភិវឌ្ឍន៍របស់ក្រុមហ៊ុនក្នុងស្រុក ។ យោងតាមទ្រឹស្តីពាណិជ្ជកម្មថ្មី និងទ្រឹស្តីកំណើនថ្មី ចំណាយច្រើនៗសំរាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ គឺជាប្រភពដ៏រឹងមាំនៃលទ្ធផលសេដ្ឋកិច្ចជាដុំកំភួន (ឥទ្ធិពលខាងក្រៅ)[១] ។ នៅក្នុងស្ថានភាពខ្លះ សេដ្ឋកិច្ចមាត្រដ្ឋាន គឺជាលទ្ធផលនៃគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម ដែលរដ្ឋាភិបាលដាក់អនុវត្តដើម្បីគាំទ្រដល់ក្រុមហ៊ុនក្នុងការប្រកួតប្រជែងជាអន្តរជាតិ ។ ឧបត្ថម្ភធនសំរាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ការលក់បង្ខូចថ្លៃ និងពន្ធគយ គឺជាវិធានការ ដែលមានប្រើយ៉ាងច្រើននៅក្នុងគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្មសព្វថ្ងៃ ។

ពាណិជ្ជកម្មនឹងមិនកើតមានឡើងទេ បើសិនថ្លៃដឹកជញ្ជូនវាខ្ពស់ជាងគំលាតរវាងតំលៃឯកតារបស់ប្រទេសនីមួយៗ ។ តំលៃដឹកជញ្ជូនបង្កឧបសគ្គចំពោះពាណិជ្ជកម្ម និងច្រើនជះឥទ្ធិពលទៅលើទំហំ និងទីតាំងនៃក្រុមហ៊ុន ។ នៅក្នុងគំរូតំបន់កណ្តាល-ជាយ (centre-periphery model) លោក Krugman (1991) បានសន្និដ្ឋានថា តំលៃដឹកជញ្ជូនខ្ពស់នឹងបង្ខំឱ្យផលិតករជ្រើសរើសទីតាំងផលិតកម្មនៅជិតទីផ្សារ ដែលនាំឱ្យកើតមានមជ្ឈមណ្ឌលផលិតកម្មប្រមូលផ្តុំធំៗ ហើយរឿងនេះនឹងនាំឱ្យមានកំណើនប្រាក់ចំណូលកើនឡើងជាលំដាប់ ។ តំលៃដឹកជញ្ជូនខ្ពស់ នឹងធ្វើឱ្យពាណិជ្ជកម្មឈប់ដំណើរការ និងកាត់ផ្តាច់ទំនាក់ទំនងរវាងតំបន់កណ្តាល និងតំបន់ជាយ ។ តំលៃដឹកជញ្ជូនទាប វាជួយសំរួលពាណិជ្ជកម្ម និងផ្តល់ផលប្រយោជន៍ដល់ប្រទេសអ្នកធ្វើពាណិជ្ជកម្ម ។ ដូច្នេះ វិបុលភាពនឹងកើនឡើងតាមការកាត់បន្ថយតំលៃដឹកជញ្ជូន ។

ពាណិជ្ជកម្មដែលមានការប្រកួតប្រជែងមិនល្អឥតខ្ចោះ គឺជាមូលហេតុនៃទំនាស់ភាគច្រើនខាងពាណិជ្ជកម្ម ។ ក្នុងនេះ ពាណិជ្ជកម្មផលិតផលកសិកម្មនៅតែជាឧបសគ្គធំបំផុតសំរាប់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុង WTO និង AFTA ទោះបីការរួមចំណែកខាងសេដ្ឋកិច្ចនៃកសិកម្មនៅក្នុងផសស នៅជុំវិញពិភពលោក បានថយចុះយ៉ាងខ្លាំងក្នុងពីរ-បីទសវត្សរ៍ចុងក្រោយក្តី ។ ក្នុងប្រទេសអភិវឌ្ឍន៍ កសិកម្មមានចំណែកតែ ១.៨% ក្នុងផសស ប៉ុន្តែវិស័យនេះនៅតែមានច្បាប់ការពារផលិតផលក្នុងស្រុកច្រើនជាងគេ (Martin and Anderson 2006:3) ។ ផ្នែកនេះពិភាក្សាពីផលប៉ះពាល់នៃពាណិជ្ជកម្មទៅលើការអភិវឌ្ឍន៍ប្រទេសជាប់ទាក់ទិន ។ ផ្នែកជាបន្ទាប់ផ្តោតលើឥទ្ធិពលគោលនយោបាយពាណិជ្ជកម្មនៅក្នុង GMS និងពិភាក្សាពីមូលហេតុដែល GMS ត្រូវខិតខំជំរុញពាណិជ្ជកម្មក្នុងតំបន់ ។

## ជួញជិត រឺ ជួញឆ្ងាយ?

### *គោលនយោបាយពាណិជ្ជកម្មនៅ GMS*

ដូចបានលើកឡើងនៅខាងលើ កសិកម្មមានតួនាទីយ៉ាងសំខាន់សំរាប់សេដ្ឋកិច្ច និងសង្គមនៃបណ្តាប្រទេស GMS ដែលមានតំរូវការបង្កើនកសិកម្មដើម្បីកាត់បន្ថយភាពក្រីក្រនៅជនបទ ដូចបានព្រមព្រៀងនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្មនៅ GMS នាថ្ងៃទី១០ សីហា ២០០៧ ក្នុងទីក្រុងប៉េកាំង ។ ពាណិជ្ជកម្មផលិតផលកសិកម្ម ជាពិសេសទាក់ទិននឹងការនាំចេញ បានជួយពង្រឹងតួនាទីកសិកម្មក្នុងការងារអភិវឌ្ឍន៍ ។ រឿងនេះ ពិតជាក់ស្តែងខ្លាំងណាស់សំរាប់ ប្រទេសដែលគ្រប់គ្រងពាណិជ្ជកម្មដោយផ្តោតលើកំណើនផ្អែកលើចំនួនការងារ ។

ពាណិជ្ជកម្មចាំបាច់បំផុតសំរាប់ការអភិវឌ្ឍន៍កសិកម្ម និងការកាត់បន្ថយភាពក្រីក្រ ហើយយុទ្ធសាស្ត្រពាណិជ្ជកម្មកសិកម្ម ក៏មានច្រើនយ៉ាងដែរ អាស្រ័យលើភាពសំបូរធនធាន ប្រវត្តិសាស្ត្រ សន្តិសុខស្បៀង ប្រភពចំណូលរដ្ឋាភិបាល ជញ្ជីងទូទាត់ និងសមត្ថភាពទំនិញជ្រៀតចូលទៅទីផ្សារផ្សេងៗ ។ល។ នាពេលសព្វថ្ងៃ ពាណិជ្ជកម្មកសិកម្មនៃប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនបានជួបឧបសគ្គ ។ បញ្ហារារាំងចំបងបំផុតដល់ការធ្វើពាណិជ្ជកម្មកសិកម្មជាមួយប្រទេសអភិវឌ្ឍន៍ដូចជា ជប៉ុន អឺរ៉ុប និងអាមេរិក អាចបែងចែកបានជាបីប្រភេទ: (១) នៅឆ្ងាយពីទីផ្សារនិងហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្មទន់ខ្សោយ (២) ពន្ធគយនិងរបាំងមិនមែនពន្ធគយ និងវិធានការការពារផ្សេងៗ (៣) តំរូវការពីក្រៅប្រទេសមានកំរិត និងអស្ថិរភាពទីផ្សារ ។

*នៅឆ្ងាយពីទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្មទន់ខ្សោយ:* ប្រទេស GMS នៅឆ្ងាយពីទីផ្សារសក្តានុពល ដែលស្ថិតក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ ។ ការដឹកជញ្ជូនផ្លូវឆ្ងាយត្រូវចំណាយច្រើន ដែលកាត់បន្ថយសមត្ថភាពប្រកួតប្រជែងរបស់ទំនិញ ។ ម្យ៉ាងទៀត ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសតិចតួចក្នុងការកែលំអហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម គួបផ្សំនឹងបរិមាណនាំចេញតិចពីប្រទេស GMS នីមួយៗ ធ្វើឱ្យចំណាយលក់ដូរទំនិញមួយមុខៗបែបនេះ ឡើងខ្ពស់ជាងចំណាយក្នុងការនាំចេញទំនិញដុំ ។ ម្យ៉ាងទៀត ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ និងបទប្បញ្ញត្តិគ្មានប្រសិទ្ធភាព ក៏អាចបង្កើនចំណាយដឹកជញ្ជូនដែរ ។ ក្នុងស្ថានភាពបែបនេះ ការជួញជិតៗ មានទាំងជំនួញជាមួយបណ្តាប្រទេស GMS ផង វាផ្តល់ផលប្រយោជន៍ច្រើនជាងការជួញទៅឆ្ងាយៗ ។

*ពន្ធគយ របាំងមិនមែនពន្ធគយ និងវិធានការការពារផ្សេងៗ:* គោលនយោបាយពាណិជ្ជកម្មដ៏សាមញ្ញបំផុតគឺ ការយកពន្ធលើទំនិញនាំចូល (ពន្ធគយ) ។ ពន្ធគយ ជាគោលនយោបាយដ៏យូរលង់បំផុតមួយ ដែលបានប្រើប្រាស់តាំងពីដើមរៀងមកសំរាប់ធ្វើជាប្រភពចំណូលរដ្ឋ និងជាមធ្យោបាយបង្កើនតំលៃទំនិញនាំចូល ដើម្បីការពារថ្លៃផលិតផលនៅក្នុងស្រុក ។ បណ្តាប្រទេសអភិវឌ្ឍន៍ ដូចជា ជប៉ុន អឺរ៉ុប និងសហរដ្ឋអាមេរិក នៅតែយកពន្ធគយខ្ពស់លើផលិតផលកសិកម្ម ។ ជាបន្ថែមលើឧបត្ថម្ភធនដែលរដ្ឋាភិបាលប្រទេសអភិវឌ្ឍន៍ផ្តល់ឱ្យកសិកររបស់ខ្លួន រដ្ឋក៏បានប្រើប្រាស់របាំងមិនមែនពន្ធគយ និងវិធានការការពារផ្សេងៗ ដើម្បីកាត់បន្ថយការនាំចូលកសិផលមានតំលៃថោកពីប្រទេសកំពុងអភិវឌ្ឍន៍ដែរ ។ ដូច្នេះការប្រឹងប្រែងជំរុញទីផ្សារកសិកម្មក្នុងតំបន់ (បណ្តាប្រទេស GMS) គឺជាយុទ្ធសាស្ត្រដ៏ល្អមួយដើម្បីអភិវឌ្ឍកសិកម្មក្នុងប្រទេសទាំងនេះ ។

*តំរូវការពីក្រៅប្រទេសមានកំរិត និងអស្ថិរភាពទីផ្សារ:* ជាទូទៅ ថ្លៃទំនិញមូលដ្ឋាន មិនកើនថែមទេ នៅពេលចំណូលក្នុងមនុស្សម្នាក់កើនឡើង ។ ការនាំចេញបន្ថែម អាចធ្វើអោយថ្លៃនៅទីផ្សារពិភពលោកធ្លាក់ចុះ សំរាប់ផលិតផលដែលមានតំរូវការស្ទើក មិនសូវកើនឡើង ។ ដូច្នេះប្រទេសកំពុងអភិវឌ្ឍន៍ក៏ព្រួយបារម្ភថា ផលិតផលមូលដ្ឋានដែលខ្លួនខំផលិត វាមានតំរូវការស្ទើកនៅប្រទេសអភិវឌ្ឍន៍ ។ ម្យ៉ាងទៀត តាមការពិនិត្យឃើញជាក់ស្តែង ប្រទេសអភិវឌ្ឍន៍តែងខំការពារផលិតផលមូលដ្ឋានរបស់ខ្លួន ជាងផលិតផលឧស្សាហកម្មទៅទៀត ។ ពួកគេតែងជួយទ្រទ្រង់ថ្លៃនៅកសិដ្ឋានឱ្យវានៅខ្ពស់ជាងកំរិតថ្លៃលំនឹងនៅទីផ្សារ ដើម្បីជួយទ្រទ្រង់ដល់ ចំណូលកសិដ្ឋាន ហើយជាទូទៅវានាំឱ្យមានការដាក់កំហិតតឹងរឹងលើទំនិញនាំចូល ។ រីឯប្រទេសកំពុងអភិវឌ្ឍន៍វិញ ពួកគេច្រើនតែរើសអើងចំពោះកសិកម្ម ដែលធ្វើឱ្យថ្លៃនៅកសិដ្ឋានឡើងចុះជាខ្លាំង និងនាំឱ្យការផ្គត់ផ្គង់ផលិតផលគ្មានស្ថិរភាព ។

ដោយសារកំហិតនានាខាងលើ ហើយការចរចានៅអង្គការពាណិជ្ជកម្មពិភពលោក (WTO) ស្តីពីសាកលភាវូបនីយកម្មពាណិជ្ជកម្មកសិកម្ម ក៏មិនទាន់បានទទួលជោគជ័យ បណ្តាប្រទេសមហាអនុតំបន់មេគង្គ (GMS) គួរពិចារណាជំរុញពាណិជ្ជកម្មក្នុងតំបន់ ជាជាងផ្តោតលើទីផ្សារក្នុងប្រទេសអភិវឌ្ឍន៍ ។ នៅពេលហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅ GMS កំពុងត្រូវបានកែលំអ ប្រទេសនីមួយៗគួរយកចិត្តទុកដាក់ និងស្វែងរកជំនាញឯកទេសក្នុងការផលិតដំណាំណាដែលពួកគេ មានឧត្តមភាពខ្ពស់បំផុតខាងថ្លៃដើម ហើយធ្វើការនាំចូលផលិតផលឯទៀតដែលពួកគេមិនអាចផលិតវាក្នុងតំលៃថោកបាន ។ ក្នុងពេលជាមួយគ្នា ប្រទេសនៅ GMS ទាំងអស់គួរធ្វើការរួមគ្នាក្នុងលក្ខណៈជាអង្គភាពតំបន់មួយ ដើម្បីធ្វើឱ្យកសិកម្មកាន់តែមានសមត្ថភាពប្រកួតប្រជែង និងអាចនាំចេញទៅតំបន់ផ្សេងៗទៀត ។

*ទស្សនវិស័យអភិវឌ្ឍន៍លើផលិតផលកសិកម្មមួយចំនួននៅកម្ពុជា*

ច្រកផ្លូវឆ្លងពីប្រទេសមួយទៅប្រទេសមួយ កំពុងត្រូវបានអភិវឌ្ឍន៍នៅក្នុង GMS ។ ក្នុងបញ្ហាបើកចំហច្រកព្រំដែន ប្រទេសនៅ GMS បានបោះជំហានធំៗទៅមុខ ដោយបានព្រមព្រៀងគ្នាលើវិធានការសំរបសំរួលពាណិជ្ជកម្មជាច្រើន ដូចជាការត្រួតពិនិត្យធ្វើតែមួយលើកនៅច្រកព្រំដែនសំខាន់ៗជាដើម ។ កម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងមួយជាមួយថៃ ដើម្បីសំរបសំរួលការឆ្លងកាត់ព្រំដែន ដោយចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៦ នៅច្រកប៉ោយប៉ែត-អរញ្ញ ។ កម្ពុជា និងវៀតណាម ក៏បានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀងមួយស្រដៀងគ្នា សំរាប់ច្រកបាវិត-ម៉ុកបៃ នៅពាក់កណ្តាលឆ្នាំ២០០៦ ។

កិច្ចព្រមព្រៀងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន GMS ដែលចាប់អនុវត្តនៅខែវិច្ឆិកា ១៩៩៩ ពីដំបូងជាកិច្ចព្រមព្រៀងត្រីភាគីរវាងឡាវ ថៃ និងវៀតណាម ហើយក្រោយមកចូលរួមដោយកម្ពុជានៅឆ្នាំ២០០១ ចិននៅឆ្នាំ២០០២ និងភូមា នៅឆ្នាំ២០០៣ ។ កិច្ចព្រមព្រៀងនេះ មានគោលដៅសំរបសំរួលចលនាទំនិញ និងប្រជាជនឆ្លងកាត់ព្រំដែន ដោយផ្តោតលើការត្រួតពិនិត្យតែមួយលើក និងបែបបទទិដ្ឋាការយ៉ាងសាមញ្ញ ។ ការឆ្លងកាត់ព្រំដែនងាយស្រួលជាងមុន ជាគន្លឹះមួយសំរាប់ទាក់ទាញកសិ-ឧស្សាហកម្មថៃ និងវៀតណាម ឱ្យមកធ្វើវិនិយោគកសិកម្មនៅកម្ពុជា ។ វិនិយោគិនមានការចាប់អារម្មណ៍លើផលិតផលពីរមុខគឺ កៅស៊ូ និងដំឡូងមី ដែលត្រូវបានដាំដុះនៅកម្ពុជា ហើយនាំចេញទៅថៃ និងវៀតណាម បន្ទាប់មកនាំចេញបន្តទៅចិនក្រោយពេលបានកែច្នៃ និងវេចខ្ចប់ ។ ការនាំចូលគោក្របីក្រៅផ្លូវការពីថៃមកកម្ពុជាសំរាប់ការប្រើប្រាស់ក្នុងស្រុក រួចហើយនាំចេញបន្តទៅវៀតណាម គេបានពិនិត្យឃើញតាំងពីមុនពេលកម្ពុជា បានចុះអនុស្សារណៈព្រមព្រៀងជាមួយប្រទេសទាំងពីរទៅទៀត ។ McNaughton (2004) បានប៉ាន់ស្មានថាការនាំចេញគោក្របីរស់ពីកម្ពុជាទៅវៀតណាម ថៃ និងម៉ាឡេស៊ី នៅឆ្នាំ១៩៩២ មានចំនួនជាក់ស្តែងច្រើនជាងតួលេខរាយការណ៍ដប់ដង ។ ក្រោយឆ្នាំ២០០៥ ចលនាឆ្លងកាត់ព្រំដែនក្រៅផ្លូវការបានថយចុះ ដែលប្រហែលមកពីមានការសំរបសំរួលខាងពាណិជ្ជកម្ម ។

ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្មនៅ GMS នាថ្ងៃទី១០ សីហា ២០០៧ នៅក្រុងប៉េកាំង រដ្ឋមន្ត្រីទាំងអស់បានបញ្ជាក់អះអាងសាជាថ្មីពីសារៈសំខាន់នៃកសិកម្មក្នុងការកាត់បន្ថយភាពក្រីក្រ ពីព្រោះប្រជាជនរាប់លាននាក់ដែលរស់នៅតាមជនបទ មានជីវភាពពឹងផ្អែកលើកសិកម្ម ។ រដ្ឋមន្ត្រីបានប្តេជ្ញាបន្តការគាំទ្រដល់ការងាររបស់ក្រុមការងារកសិកម្ម (WGA) នៅ GMS ។ ការងារកសិកម្មដែលអនុវត្តក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការ GMS ហាក់ដូចមានប្រសិទ្ធភាពល្អ ក្នុងការជំរុញកំណើនពាណិជ្ជកម្ម និងការផ្លាស់ប្តូរបច្ចេកទេសកសិកម្ម ។ ឧ. អ្នកបច្ចេកទេសកសិកម្មកម្ពុជាជាច្រើននាក់ បានទទួលការបណ្តុះបណ្តាលនៅ ចិន ថៃ និងវៀតណាមស្តីពីវារីវប្បកម្ម ការចិញ្ចឹមសត្វ ការត្រួតពិនិត្យ និងទប់ស្កាត់ជំងឺសត្វឆ្លងកាត់ព្រំដែន និងការប្រើប្រាស់ដី ។ ចិនដែលមានបច្ចេកទេសកសិកម្មជឿនលឿនជាងគេ បានយល់ព្រមផ្តល់ការបណ្តុះបណ្តាលលើការងារអនុវត្តន៍ជាក់ស្តែងខាងកសិកម្ម ដល់បណ្តាប្រទេសនៅ GMS ។ ទោះបីកម្ពុជា ត្រូវប្រឈមមុខនឹងកំហិតមួយចំនួននៅក្នុងកម្មវិធីអភិវឌ្ឍន៍កសិកម្មនៅ GMS ដោយសារមានការប្រកួតប្រជែងខ្លាំងក្នុងផលិតផលប្រភេទខ្លះពីសំណាក់ប្រទេសមានកំរិតអភិវឌ្ឍន៍ខ្ពស់ជាង ជាពិសេស ថៃ និងវៀតណាម ប៉ុន្តែគេនៅតែអាចជំរុញការអភិវឌ្ឍន៍កសិកម្មបានតាមរយៈការកសាងសមត្ថភាព និងការផ្តល់ឱកាសសំរាប់នាំចេញ ។ ផលិតផលកសិកម្មចំបងៗមួយចំនួននៅកម្ពុជា (ឧ. ដំឡូងមី និងកៅស៊ូ) នៅតែមានអនាគតភ្លឺស្វាង ប៉ុន្តែផលិតផលមួយចំនួនទៀតត្រូវពឹងផ្អែកលើការកែលំអសមត្ថភាពប្រកួតប្រជែងរបស់វា ។

## សន្និដ្ឋាន

ពាណិជ្ជកម្មមិនមែនជាឱសថទិព្វសំរាប់ការអភិវឌ្ឍន៍ទេ ប៉ុន្តែបើគ្មានវាការអភិវឌ្ឍន៍មិនអាចដំណើរការបានប្រសើរឡើយ ។ យើងយល់ស្របថា "គ្មានការជួញដូរ គឺគ្មានការអភិវឌ្ឍន៍" ប៉ុន្តែកម្ពុជាត្រូវតែកែលំអសមត្ថភាពប្រកួតប្រជែងរបស់ខ្លួនតាមរយៈការពង្រីក និងឯកទេសនីយកម្មផលិតកម្ម ។

លក្ខខណ្ឌចាំបាច់សំរាប់ពាណិជ្ជកម្ម គឺផលិតផលមានលក្ខណៈប្រកួតប្រជែង ។ ប៉ុន្តែលក្ខខណ្ឌនេះគ្មានប្រយោជន៍អ្វីទេ បើសិនចំណាយដឹកជញ្ជូនវាខ្ពស់ជាងគំលាតរវាងថ្លៃទំនិញនៅប្រទេសនាំចូល និងថ្លៃទំនិញនោះនៅប្រទេសនាំចេញ ។ ចំណាយខ្ពស់លើការដឹកជញ្ជូន វាប៉ះពាល់ពាណិជ្ជកម្មគ្រប់ប្រភេទ ។ នៅពេលប្រទេសមួយមានសមត្ថភាពផលិតប្រកួតប្រជែង និងមានចំណាយដឹកជញ្ជូនទាបហើយ គេត្រូវតែជ្រៀតចូលទីផ្សារអន្តរជាតិឱ្យបាន ។

សំរាប់ការអភិវឌ្ឍន៍កសិកម្មកម្ពុជា គឺមានផលិតផលមួយចំនួនដែលមានសក្តានុពលសំរាប់ការនាំចេញ ដូចជា ដំឡូងមី កៅស៊ូ អង្ករ ជាដើម ។ គេអាចឃើញនូវឱកាសច្រើនទៀតសំរាប់នាំចេញផលិតផលទាំងនោះ បើសិនមានការកែលំអផលិតភាព និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារ ។ កំណើនទីផ្សារនៅ GMS ជាកត្តាជំរុញដល់ការជួញដូរផលិតផលបែបនេះ ។ នៅពេលមានទីផ្សារក្នុងតំបន់ហើយ កម្ពុជាគួរពិចារណាកាត់បន្ថយចំណាយប្រតិបត្តិការ និងចំណាយដឹកជញ្ជូន ហើយគួបផ្សំនឹងការកែលំអផលិតភាព វានឹងជួយបង្កើនពាណិជ្ជកម្មកសិកម្ម និងប្រាក់ចំណូលរបស់ប្រជាជនដែលរស់នៅអាស្រ័យដោយកសិកម្ម ។

## កំណត់សំគាល់

១. ទ្រឹស្តីបែបក្លាសិកនៃការរីកលូតលាស់ បានមើលរំលងយ៉ាងយូរនូវឥទ្ធិពលទាំងនេះ ។

២. ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានជួយដល់ GMS តាំងពីពេលគិតគូរបង្កើតតំបន់នេះឡើងនៅឆ្នាំ១៩៩២ ។

## ឯកសារយោង


Krugman, Paul R. & Maurice Obstfeld (2003), International Economics: Theory and Policy, Sixth Edition (New York: Harper Collins Publishers)

Martin, Will & Kym Anderson (2006), Agricultural trade reform and the Doha development agenda (Washington, DC: World Bank).

McNaughton, Andrew (2004), Animal Production System (in Cambodia) in the Political Economy of Pro-Poor Livestock Policy in Cambodia, Sophal Ear and David K. Leonard, eds., University of California, Berkeley

Norton, George W. & Jeffrey Alwang (1993), Introduction to Economics of Agricultural Development (McGraw-Hill)

Riddell, Tom, Jean Shackelford, Steve Stamos & Geoffrey Schneider (2002), Economics: a tool for critically undertanding society, 6th ed. (Addison Wesley)

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

ផសស ពិតនៅ US កើន ១,៩% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី១ ២០០៧ ធៀបនឹងកំណើន ៣,១% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៤ ២០០៦ ។ នេះបណ្ដាលមកពីកំណើនការនាំចូល ការធ្លាក់ចុះការនាំចេញ ការថយចុះចំណាយរដ្ឋាភិបាលសហព័ន្ធ និងការធ្លាក់ល្បឿនកំណើនចំណាយប្រើប្រាស់ផ្ទាល់ខ្លួន ។ នៅត្រីមាសទី១ ២០០៧ ផសស ពិតនៅតំបន់អឺរ៉ូ មានកំណើន ៣,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និង ០,៦% ធៀបនឹងត្រីមាសមុន ។ ផសស ពិតនៅជប៉ុនកើន ២,២% ធៀបនឹងឆ្នាំមុន និងកើន ០,៦% ធៀបនឹងត្រីមាសមុន ។

នៅត្រីមាសទី១ ២០០៧ ចិន មានកំណើនសេដ្ឋកិច្ច ១១,១% ធៀបនឹងកាលពីមួយឆ្នាំមុន ។ កំណើននេះ នាំមុខដោយឧស្សាហកម្មដែលមានកំណើន ១៣,២% ធៀបនឹង ៩,៩% ក្នុងវិស័យសេវាកម្ម និង ៤,៤% ក្នុងវិស័យកសិកម្ម ។ វិនិយោគ និងពាណិជ្ជកម្ម នៅតែជាកំលាំងជំរុញចំបងដល់កំណើនសេដ្ឋកិច្ចនេះ ។ នៅត្រីមាសទី១ ផសស ពិតនៅកូរ៉េខាងត្បូង កើន ៤,០% ធៀបនឹងកាលពីមួយឆ្នាំមុន និងកើន ០,៩% ធៀបនឹងត្រីមាសមុន ។ នៅត្រីមាសដដែល ផសស ពិត នៅតៃវ៉ាន់ និងហុងកុង កើន ៤,១% និង ៥,៦% ធៀបនឹងកាលពីមួយឆ្នាំមុន ។

សេដ្ឋកិច្ចនៅម៉ាឡេស៊ី កើន ៥,៣% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី១ ២០០៧ ។ កំនើនក្នុងត្រីមាសនេះ មានមូលដ្ឋានទូលាយដោយស្ទើរគ្រប់វិស័យចំបងៗសុទ្ធតែមានកំនើនលើកលែងតែការជីកយករ៉ែ ។ វិស័យសេវាកម្ម និងការរីកលូតលាស់កាន់តែលឿនក្នុងផ្នែកសំណង់ជាកត្តាគន្លឹះ ជំរុញឱ្យមានកំនើនសេដ្ឋកិច្ច ។ នៅត្រីមាសទី១ ២០០៧ ផសស ពិតនៅសិង្ហបុរី កើន ៦,០% ធៀបនឹងកាលពីមួយឆ្នាំមុន ។ ឧស្សាហកម្មផលិត និងសំណង់ កើន ៦,១% និង ៧,០% រីឯសេវាកម្ម កើន ៦,១% ។ ផសស ពិត នៅថៃ មានកំនើន ៤,៣% ។ វិស័យកសិកម្ម មានកំណើន ៤,៣% ធៀបនឹងកំណើន ១,៩% នៅត្រីមាសមុន ដោយសារផលដំណាំ និងផលនេសាទបានកើនឡើង ។ វិស័យមិនមែនកសិកម្ម ក៏កើន ៤,៣% ដែរ ធៀបនឹងកំណើន ៤,៦% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី៤ ២០០៦ ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់នៅទីផ្សារអន្តរជាតិ

នៅត្រីមាសទី១ ២០០៧ ថ្លៃទំនិញប្រើប្រាស់នៅ US កើនតាមអត្រាប្រចាំឆ្នាំ ២,៤% ធៀបនឹងកំណើន ១,៩% នៅត្រីមាសមុន ។ រឿងនេះ បណ្ដាលមកពីកំណើនថ្លៃម្ហូបអាហារ ថ្នាំពេទ្យ ផ្ទះស្នាក់នៅ និងថាមពល ។ នៅតំបន់អឺរ៉ូវិញ មានអតិផរណា ១,៩% ធៀបនឹងអតិផរណា ១,៨% នៅត្រីមាសមុន ។ កំនើននេះ ជំរុញដោយការឡើងថ្លៃធាតុចូល និងថ្លៃថាមពល ព្រមទាំងការតំលើងអាករលើតំលៃបន្ថែមនៅអាឡឺម៉ង់នាពេលថ្មីៗនេះ ។ នៅជប៉ុន ថ្លៃទំនិញប្រើប្រាស់ ធ្លាក់ចុះ ០,១% ក្នុងរយៈមួយឆ្នាំដល់ត្រីមាសទី១ ដោយសារជាសំខាន់ការចុះថ្លៃទូរគមនាគមន៍ ។ ប៉ុន្តែ អត្រាប្រែប្រួលនេះវាតិចតួចសឹងស្មើ 0% បើគេមិនរាប់បញ្ចូលនូវផលិតផលប្រេងកាត និងកត្តាពិសេសៗផ្សេងទៀត ។

នៅទីផ្សារប្ដូរប្រាក់អន្តរជាតិ ដុល្លារUSប្រែប្រួលចំរុះ ទល់នឹងរូបិយវត្ថុដទៃទៀត ។ ទល់នឹងប្រាក់យ៉េនជប៉ុន វាប្ដូរបាន ១១៩,៤យ៉េន/ដុល្លារUS ធៀបនឹង ១១៧,៨យ៉េន/ដុល្លារUSនៅត្រីមាសមុន ។ ការឡើងថ្លៃដុល្លារUS នេះ វាទាក់ទងនឹងការរំពឹងទុករបស់ទីផ្សារអំពីគោលនយោបាយហិរញ្ញវត្ថុនៅជប៉ុន ។ ទល់នឹងប្រាក់អឺរ៉ូ និងប្រាក់យ៉ុនចិន ដុល្លារUS ប្ដូរបាន ០,៧៦អឺរ៉ូ/ដុល្លារUS និង ៧,៧៦យ៉ុន/ដុល្លារUS គឺធ្លាក់ថ្លៃ បើធៀបនឹងអត្រា ០,៧៨អឺរ៉ូ/ដុល្លារUS និង ៧,៨៦យ៉ុន/ដុល្លារUSនៅត្រីមាសទី៤ ២០០៦ ។ ការធ្លាក់ថ្លៃដុល្លារUS មួយភាគធំបណ្ដាលមកពីប្រតិកម្មនៃទីផ្សារចំពោះការថយចុះកំណើនសេដ្ឋកិច្ចនៅUS នៅពេលដែលប្រទេសមានសេដ្ឋកិច្ចធំៗឯទៀត និងប្រទេសមួយចំនួននៅអាស៊ាន កំពុងបន្តមានកំណើនសេដ្ឋកិច្ចខ្លាំងក្លា ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ២០០៧ ពោត ប្រេងឆា សណ្ដែកសៀង អង្ករ និងសាំង ឡើងថ្លៃ រីឯប្រេងឆៅ និងម៉ាស៊ូត ធ្លាក់ថ្លៃ ។ ប្រេងឆាលក់បាន ៥៥២,០៦ ដុល្លារ/តោន ធៀបនឹង ៤៩៤,៩២ដុល្លារ/តោន នៅត្រីមាសទី៤ ២០០៦ ។ ពោត និងសណ្ដែកសៀង លក់ថ្លៃ ១៥៤,៣៣ដុល្លារ/តោន និង ២៥៥,៣៣ ដុល្លារ/តោន ។ អង្ករ Thai 100%B លេខ២ នៅទីផ្សារបាងកក លក់ថ្លៃ ២៩៤,១៧ដុល្លារ/តោន ធៀបនឹង ២៧៩,១០ដុល្លារ/តោននៅត្រីមាសទី៤ ។ ថ្លៃសាំងនៅត្រីមាសទី១ ២០០៧ កើន ១,៧% ធៀបនឹងត្រីមាសមុន ដល់ ៧១,៧១សេន/លីត្រ រីឯថ្លៃប្រេងឆៅ និងម៉ាស៊ូតធ្លាក់ចុះ ៣,៩% និង ១,១% ។ ប្រេងឆៅ លក់ថ្លៃ ៥៨,២១ដុល្លារ/ធុង និងម៉ាស៊ូត ៤៥,៦១ដុល្លារ/ធុង។

*រៀបរៀងដោយ ហ៊ីង វុត្ថា និង ភឹម រុនស៊ីណារិទ្ធិ*

**តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)**

| | 2001 | 2002 | 2003 | 2004 | 2005 | 2006* | 2006 Q2 | 2006 Q3 | 2006 Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 8.0 | 6.5 | 8.5 | 10.0 | 13.5 | 10.8 | -1.6 | - | - | - |
| ឥណ្ឌូនេស៊ី | 3.8 | 3.8 | 4.9 | 5.1 | 5.6 | 5.4 | 5.2 | 5.5 | 6.1 | - |
| ម៉ាឡេស៊ី | 0.5 | 5.6 | 5.4 | 7.0 | 5.2 | 5.9 | 5.9 | 5.8 | 5.7 | 5.3 |
| សិង្ហបុរី | -2.3 | 2.6 | 1.4 | 8.5 | 5.7 | 7.7 | 8.0 | 7.1 | 7.0 | 6.0 |
| ថៃ | 1.9 | 6.1 | 6.9 | 6.0 | 4.5 | 4.8 | 4.9 | 4.7 | 4.2 | 4.3 |
| វៀតណាម | 6.0 | 6.7 | 7.0 | 7.5 | 8.4 | 8.1 | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 7.5 | 8.1 | 9.9 | 9.5 | 9.6 | 10.5 | 11.3 | 10.4 | 10.7 | 11.1 |
| ហុងកុង | 0.5 | 5.0 | 3.2 | 8.3 | 6.5 | 6.6 | 5.2 | 6.8 | 7.0 | 5.6 |
| កូរ៉េខាងត្បូង | 3.0 | 6.1 | 3.0 | 4.7 | 4.7 | 5.0 | 5.3 | 4.8 | 5.0 | 4.0 |
| តៃវ៉ាន់ | -2.2 | 4.2 | 3.1 | 5.7 | 4.1 | 4.6 | 4.6 | 5.0 | 4.0 | 4.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.4 | 0.7 | 0.5 | 1.8 | 1.5 | 2.7 | 2.4 | 2.6 | 3.3 | 3.0 |
| ជប៉ុន | 0.4 | 0.4 | 2.6 | 3.4 | 2.5 | 2.1 | 2.2 | 2.7 | 2.3 | 2.2 |
| សហរដ្ឋអាមេរិក | 1.2 | 2.4 | 3.1 | 4.4 | 3.7 | 3.3 | 3.5 | 3.3 | 3.1 | 1.9 |

*Sources: Economist, countries' national statistics offices and central banks and ADB's Asia Regional Information Centre*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## តារាង ២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.6 | 3.2 | 1.2 | 4.0 | 5.8 | 4.7 | 4.5 | 4.9 | 3.4 | 3.0 |
| ឥណ្ឌូនេស៊ី | 11.5 | 13.2 | 8.3 | 8.3 | 10.5 | 13.4 | 15.5 | 14.9 | 6.1 | 6.4 |
| ម៉ាឡេស៊ី | 1.4 | 1.8 | 1.1 | 1.6 | 3.1 | 3.7 | 4.1 | 3.6 | 3.1 | 2.6 |
| សិង្ហបុរី | 1.0 | -0.4 | 0.5 | 1.7 | 0.5 | 1.0 | 1.2 | 0.7 | 0.6 | 0.5 |
| ថៃ | 1.7 | 0.6 | 1.8 | 2.7 | 4.5 | 4.7 | 6.0 | 3.6 | 3.3 | 2.4 |
| វៀតណាម | -0.4 | 3.8 | 3.1 | 7.8 | 8.2 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.9 | -0.7 | 1.2 | 3.9 | 1.8 | 1.5 | 1.4 | 1.4 | 1.8 | 2.6 |
| ហុងកុង | -1.3 | -3.0 | -2.6 | -0.4 | 1.1 | 2.2 | 2.1 | 2.3 | 2.2 | 1.7 |
| កូរ៉េខាងត្បូង | 4.4 | 2.7 | 3.5 | 3.5 | 2.8 | 2.4 | 2.3 | 2.5 | 2.4 | 2.0 |
| តៃវ៉ាន់ | -0.01 | -0.2 | -0.3 | 1.6 | 2.3 | 0.6 | 1.5 | -0.3 | -0.1 | 1.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | 0.0 | | | | |
| អឺរ៉ូ-១២ | 2.6 | 2.2 | 2.1 | 2.2 | 2.2 | 2.1 | 2.3 | 2.1 | 1.8 | 1.9 |
| ជប៉ុន | -0.6 | -0.9 | -0.3 | Nil | -0.3 | 0.5 | 0.7 | 0.6 | 0.3 | -0.1 |
| សហរដ្ឋអាមេរិក | 2.8 | 1.6 | 2.3 | 2.7 | 3.4 | 3.2 | 4.0 | 3.3 | 1.9 | 2.4 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

## តារាង ៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3916.3 | 3912.1 | 3973 | 4016.3 | 4092.5 | 4103.2 | 4095.3 | 4125.0 | 4111.3 | 4046.7 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 10,261 | 9311 | 8577 | 8938 | 9705 | 9134 | 9115 | 9122 | 9125 | 9107 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.79 | 3.67 | 3.65 | 3.67 | 3.62 | 3.50 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.79 | 1.79 | 1.74 | 1.69 | 1.66 | 1.59 | 1.59 | 1.58 | 1.56 | 1.53 |
| ថៃ (បាត) | 44.4 | 42.9 | 41.5 | 40.2 | 40.2 | 37.9 | 38.1 | 37.7 | 36.5 | 33.9 |
| វៀតណាម (ដុង) | 14,725 | 15,280 | 15,510 | - | 15,859 | 15,994 | 15,964 | 16,015 | 16,077 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ួន) | 8.28 | 8.28 | 8.28 | 8.28 | 8.19 | 7.97 | 8.01 | 7.97 | 7.86 | 7.76 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.78 | 7.79 | 7.78 | 7.77 | 7.76 | 7.78 | 7.78 | 7.81 |
| កូរ៉េខាងត្បូង (វ៉ុន) | 1291 | 1251 | 1192 | 1145 | 1024 | 955 | 949 | 955 | 938 | 939 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.8 | 34.5 | 34.4 | 33.6 | 32.1 | 32.5 | 32.2 | 32.8 | 32.8 | 32.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 1.12 | 1.06 | 0.89 | 0.80 | 0.80 | 0.80 | 0.80 | 0.78 | 0.78 | 0.76 |
| ជប៉ុន (យ៉េន) | 121.5 | 125.4 | 115.9 | 108.2 | 110.2 | 116.4 | 114.5 | 116.3 | 117.8 | 119.4 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

## តារាង ៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០១-២០០៧ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | 2006 | 2007 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - US ($/តោន) | 81.18 | 89.98 | 95.42 | 110.65 | 89.19 | 111.04 | 99.95 | 108.67 | 140.18 | 154.33 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 259.13 | 353.91 | 402.03 | 427.47 | 381.32 | 433.85 | 397.87 | 446.85 | 494.92 | 552.06 |
| អង្ករ (Thai 100%B) – បាងកក ($/តោន) | 160.81 | 178.59 | 182.22 | 221.67 | 262.88 | 282.00 | 283.86 | 289.91 | 279.10 | 294.17 |
| សណ្តែកសៀង (US No. 1) – US ($/តោន) | 163.89 | 182.58 | 218.86 | 262.03 | 224.25 | 213.88 | 207.02 | 207.38 | 230.17 | 255.33 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 22.8 | 23.9 | 26.8 | 33.5 | 50.14 | 61.58 | 65.03 | 67.00 | 56.39 | 54.21 |
| សាំង – US Gulf coast (សេន/លីត្រ) | 19.5 | 19.1 | 23 | 30.9 | 42.19 | 47.70 | 55.89 | 52.70 | 41.02 | 41.71 |
| ម៉ាស៊ូត (ស្តង់ដ័រតិច លេខ២) – US Gulf coast (សេន/លីត្រ) | 18.72 | 17.85 | 21.63 | 29.48 | 44.35 | 51.35 | 55.89 | 55.66 | 46.11 | 45.61 |

*Sources: Food and Agriculture Organisation and US Energy Information Administration.*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុងត្រីមាសទី១ ២០០៧ ការធ្លាក់ចុះគំរោងវិនិយោគឯកជនបានអនុម័ត បានកាត់បន្ថយកំណើនសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេស ដោយសារតែវិស័យនេះជាកត្តាជំរុញយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ទោះយ៉ាងនេះក្តី គំរោងសាងសង់បានអនុម័ត និងចំនួនភ្ញៀវទេសចរណ៍មកដល់កម្ពុជា បានកើនឡើងធៀបនឹងត្រីមាសមុន ប៉ុន្តែឱនភាពពាណិជ្ជកម្ម ក៏កើនឡើងយ៉ាងខ្លាំងដែរ ។

គំរោងវិនិយោគសរុបបានអនុម័ត មាន ៤៩៧,៥លានដុល្លារ រឺថយចុះ ៤៩% ធៀបនឹងត្រីមាសមុន ។ គំរោងវិនិយោគក្នុងវិស័យកសិកម្មធ្លាក់ចុះ ៨៨% មកត្រឹម ១៩,១លានដុល្លារ និងក្នុងវិស័យសេវាកម្មធ្លាក់ចុះ ៥៥% មកត្រឹម ៣៣៥,៧លានដុល្លារ រីឯគំរោងសំរាប់វិស័យឧស្សាហកម្មវិញ កើន ៨៦% ដល់ ១៤២,៧លានដុល្លារ ។ គំរោងវិនិយោគសំរាប់វិស័យកសិកម្ម គឺសុទ្ធតែជាគំរោងកសិ-ឧស្សាហកម្មទាំងអស់ក្នុងអំឡុងពេលនេះ ។ ចំពោះគំរោងវិនិយោគក្នុងវិស័យឧស្សាហកម្ម គំរោងសំរាប់វិស័យកាត់ដេរមាន ២៦% រឺ ៣៦,៦លានដុល្លារ ដោយកើន ៤១% ធៀបនឹងត្រីមាសមុន ។ គំរោងក្នុងវិស័យទេសចរណ៍ ជាកត្តាជំរុញសំខាន់មួយនៃវិនិយោគក្នុងវិស័យសេវាកម្មដែលមានតំលៃ ១៤០,៣លានដុល្លារ រឺធ្លាក់ចុះ ៥៦% ។ នៅត្រីមាសទី១ ២០០៧ មាន ២៥គំរោង ត្រូវបានអនុម័ត ក្នុងនោះមាន ២ ជាគំរោងផ្នែកកសិកម្មដែលត្រូវការកម្មករថ្មីៗចំនួន ១៩៦៥នាក់ ។ ក្នុងនោះ វិស័យឧស្សាហកម្មមាន ១៧គំរោង និងត្រូវការកម្មករចំនួន ២៩៧៨៩នាក់ រីឯវិស័យសេវាកម្មវិញមាន ៦គំរោង និងត្រូវការកម្មករចំនួន ៣៥៧៥នាក់ ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ គំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់បានអនុម័ត បានកើនឡើងទ្វេដង ។ គំរោងក្នុងវិស័យសេវាកម្ម កើន ១ ជា ៦ នៅត្រីមាសទី១ ២០០៦ ហើយក្នុងវិស័យឧស្សាហកម្ម កើន ១ជា៤ រីឯគំរោងក្នុងវិស័យកសិកម្មធ្លាក់ចុះ ៨៥% ។ ឧត្តមភាពប្រៀបធៀបសំរាប់ការវិនិយោគនៅកម្ពុជា គឺថ្លៃដើមផលិតកម្មទាប និងមិនមានការរឹតបណ្តឹងកូតាចំពោះការនាំចេញទៅអាមេរិកនិងតំបន់អឺរ៉ូ ។ បច្ចុប្បន្នរោងចក្រកាត់ដេរភាគច្រើនមានម្ចាស់ជាជនបរទេស ហើយនៅត្រីមាសទី១ ២០០៧ មាន ៥៧% នៃគំរោងគិតជាទ្រព្យសកម្មជាប់លាប់ ជាសំនើរបស់វិនិយោគិនបរទេស ។

នៅត្រីមាសទី១ ២០០៧ គំរោងសាងសង់បានអនុម័តនៅទីក្រុងភ្នំពេញមាន ៩០,៤លានដុល្លារ រឺកើន ១៦% ធៀបនឹងត្រីមាសមុន ។ គំរោងផ្ទះល្វែងកើន ១០% ដល់ ៥៩,៩លានដុល្លារ និងគំរោងផ្ទះនិងភូមិគ្រឹះ កើន ១២% ដល់ ១០,៩លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នា ២០០៦ គំរោងសាងសង់សរុបបានអនុម័ត កើន ៣៤% ក្នុងនោះ គំរោងផ្ទះល្វែង កើន ៥០% និងផ្ទះនិងភូមិគ្រឹះ កើន ៧,៩% ។ គំរោងសាងសង់ពិតប្រាកដ នៅទីក្រុងភ្នំពេញនៅឆ្នាំ២០០៦ មាន ៣០៦,៦លានដុល្លារ (៦៨៥ គំរោង) ដែលក្នុងនោះមាន ៨៦% បានស្នើសុំការអនុញ្ញាតឱ្យសាងសង់ពីសាលាក្រុងភ្នំពេញ និងចំនួននៅសល់បានសាងសង់ដោយមិនបានសុំការអនុញ្ញាតជាមុនទេ ។

ឱនភាពពាណិជ្ជកម្មនៅកម្ពុជា កើន ១៨% ធៀបនឹងត្រីមាសមុន ដល់ ៨៣,១លានដុល្លារ ។ ការនាំចេញធ្លាក់ចុះអស់ ២ត្រីមាសបន្តបន្ទាប់គ្នា បន្ទាប់ពីកំណើននៅត្រីមាសទី៣ ២០០៦ ហើយការនាំចូលក៏ធ្លាក់ចុះដែរ បន្ទាប់ពីមានកំណើនអស់ជាច្រើនត្រីមាសកន្លងមក ។ នៅត្រីមាសទី១ ២០០៧ ការនាំចេញសរុបធ្លាក់ចុះ ៣,៩% មកត្រឹម ៧០៧,៨លានដុល្លារ ។ ការនាំចេញក្នុងវិស័យកាត់ដេរ ដូចជា សំលៀកបំពាក់ ស្បែកជើង និងផលិតផលវាយនភ័ណ្ឌផ្សេងទៀត បានធ្លាក់ចុះ ៥,៤% មកត្រឹម ៦៧៧,៥លានដុល្លារ ។ ទាំងការនាំចេញឈើ និងត្រី កើន ៣០% ដល់ ២,១លានដុល្លារ និង ០,៧លានដុល្លារ រីឯការនាំចេញកៅស៊ូ ថយចុះ ២០% មកត្រឹម ៨,៤លានដុល្លារ ។ ការនាំចេញសរុបរបស់កម្ពុជា កើន ១៧% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ ដោយការនាំចេញសំលៀកបំពាក់ កើន ២០% រីឯការនាំចេញផលិតផលកសិកម្មធ្លាក់ចុះ ១៣% ។

ការនាំចូលរបស់កម្ពុជាធ្លាក់ចុះ ២,០% ធៀបនឹងត្រីមាសមុន មកត្រឹម ៧៩០,៩លានដុល្លារ បន្ទាប់ពីកំណើន ៣ត្រីមាសមក ។ ការនាំចូលម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ ធ្លាក់ចុះ ១,៦% មកត្រឹម ៤២,៣លានដុល្លារ រីឯសំភារៈសំណង់កើន ២៤% ដល់ ៤៤,១លានដុល្លារ ។ ការនាំចូលសាំង កើន ៤,៤% ដល់ ១៥,៧លានដុល្លារ និងការនាំចូលម៉ាស៊ូត កើន ១៨% ដល់ ៣១,៩លានដុល្លារ ។ បើគិតពីបរិមាណ ការនាំចូលសាំង កើន ២០% ដល់ ៥០.៨៥០តោន និងការនាំចូលម៉ាស៊ូត កើន ២១% ដល់ ១១៥.៧៤០តោន ។ ការនាំចូលសរុប កើន ១៥% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ។

នៅត្រីមាសទី១ ២០០៧ ភ្ញៀវបរទេសមកដល់កម្ពុជាសរុបមានចំនួន ៥៥០.៨១៣នាក់ រឺកើន ៦,៧% ធៀបនឹងត្រីមាសមុន និងកើន ២០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ ។ ចំនួនភ្ញៀវមកដល់តាមផ្លូវអាកាស កើន ៣៦% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៦ ដល់ ៣៧៣.៥៩៤នាក់ ។ អាកាសយានដ្ឋានអន្តរជាតិសៀមរាបទទួលបាន ៤៣% នៃភ្ញៀវមកដល់តាមផ្លូវអាកាស និង ៥៩% នៃភ្ញៀវទៅសៀមរាប ។ ភ្ញៀវមកដល់តាមផ្លូវគោកមាន ១៦២.៥៤៧នាក់ រឺធ្លាក់ចុះ ៣,៨% ធៀបនឹងត្រីមាសដូចគ្នាមួយឆ្នាំមុន រីឯភ្ញៀវមកដល់តាមផ្លូវទឹក កើន ១៣% ដល់ ១៤.៦៧២នាក់ ។ ភ្ញៀវមកលំហែកាយមាន ៩០% នៃភ្ញៀវសរុប ។ ភ្ញៀវកូរ៉េមានច្រើនជាងគេ ដល់ ១១៨.៥៩៧នាក់ បន្ទាប់មកគឺភ្ញៀវជប៉ុន អាមេរិក និងតៃវ៉ាន់ ។

## ហិរញ្ញវត្ថុសាធារណៈ

តាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ដំណើរការរៀបចំរបាយការណ៍ថវិការដ្ឋត្រូវបានផ្លាស់ប្តូរនៅខែមករា ២០០៧ ។ បច្ចុប្បន្នសមាសភាពចំនាយចរន្តត្រូវបានរាយការណ៍ជាបៀវត្សរ៍ ការទិញរបស់រដ្ឋាភិបាល ឧបត្ថម្ភធននិងជំនួយសង្គម និងសេវាកម្មផ្សេងៗទៀត ជំនួសឱ្យការចំណាយសរុបដោយក្រសួងនីមួយៗ ដូចបានរាយការណ៍ពីមុនៗមក ។ ចំពោះការបង្ហាញពីចំណូលចរន្តនៅក្នុងរបាយការណ៍របស់ MEF មានការផ្លាស់ប្តូរបន្តិចបន្តួច ។ នៅខែមករា (ទិន្នន័យដែលមានសំរាប់ត្រីមាសទី១ ២០០៧) ថវិការបស់រដ្ឋាភិបាលមានអតិរេក ៦៥,៤ពាន់លានរៀល ធៀបនឹងឱនភាព ១២៨,៧ពាន់លានរៀលនៅអំឡុងពេលដូចគ្នាឆ្នាំ២០០៦ ។ នៅខែមករា ចំណូលសរុបមានចំនួន ២៥៨,០ពាន់លានរៀល ក្នុងនោះចំណូលបានពីពន្ធមាន ៨៦% រឺ ២២២,៥ពាន់លានរៀល ។ ពន្ធក្នុងស្រុកមាន ៦៨% នៃចំណូលពន្ធសរុប ហើយវាមានធាតុផ្សំដូចជាពន្ធលើប្រាក់ចំណេញ អាករលើផលរបរ អាករពិសេស និងពន្ធផ្សេងទៀត ។ ពន្ធលើពាណិជ្ជកម្មអន្តរជាតិ រួមមានពន្ធលើការនាំចូល និងការនាំចេញមាន ៧២,២ពាន់លានរៀល ។ ចំណូលមិនមែនពន្ធមាន ៣៥,៥ពាន់លានរៀល រឺ ១៤% នៃចំណូលសរុប ។ ចំណូលពីអចលនទ្រព្យមាន ៨,២% នៃចំណូលមិនមែនពន្ធសរុប និងការលក់ទំនិញនិងសេវាកម្មរបស់រដ្ឋាភិបាលមាន ៨៥% ។ ចំណូលមូលធន គឺសូន្យ នៅខែមករា ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

នៅខែមករា ចំនាយថវិកា មាន ១០១,៧ពាន់លានរៀល ។ ចំណាយចរន្ត មាន ២៥,៨ពាន់លានរៀល ដែលប្រាក់បៀវត្សរ៍មន្ត្រីរដ្ឋាភិបាលមាន ៥៣% ការផ្គត់ផ្គង់និងជំនួយសង្គមមាន ១៥% និងបន្ទុកចំណាយហិរញ្ញវត្ថុមាន ៦,២% ។ នៅអំឡុងពេលដូចគ្នា ចំណាយមូលធនមាន ៧៦,០ពាន់លានរៀល ភាគច្រើនជាមូលនិធិផ្តល់ដោយខាងក្រៅ និងមានតែ ១,៨%ប៉ុណ្ណោះ ដែលផ្តល់ដោយរដ្ឋាភិបាល ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ ២០០៧ ថ្លៃទំនិញ និងសេវាទូទៅនៅភ្នំពេញធ្លាក់ចុះ ០,៦% ធៀបនឹងត្រីមាសមុន ។ ថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ធ្លាក់ចុះ ១,១% ថ្លៃម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ធ្លាក់ចុះ ២,០% និងថ្លៃសំលៀកបំពាក់និងស្បែកជើងធ្លាក់ចុះ ០,៥% រីឯថ្លៃផ្ទះស្នាក់នៅនិងថ្លៃទឹកភ្លើងកើន ០,២% ថ្លៃថែទាំសុខភាព កើន ០,៣% និងថ្លៃផលិតផលថែទាំកាយ កើន ០,៦% ។ នៅរដូវប្រាំង ក្នុងត្រីមាសទី១ ឆ្នាំ២០០៧ ថ្លៃទំនិញ និងសេវាទូទៅ កើន ២,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ ដែលក្នុងនោះថ្លៃថែទាំសុខភាពកើន ២,៤% ថ្លៃម្ហូបអាហារ ភេសជ្ជៈ និងថ្នាំជក់ កើន ៣,០% ថ្លៃសំលៀកបំពាក់និងស្បែកជើង កើន ៣,៥% និងថ្លៃដឹកជញ្ជូននិងទូរគមនាគមន៍ កើន ៥,២% ។

បន្ទាប់ពីការធ្លាក់ថ្លៃនៅត្រីមាសទី៣ និងការឡើងថ្លៃនៅត្រីមាសទី៤ ២០០៦ ប្រាក់រៀលបានឡើងថ្លៃ នៅត្រីមាសទី១ ២០០៧ ដោយមានអត្រាប្តូរប្រាក់ ៤០៦៣រៀល/ដុល្លារUS រឺឡើងថ្លៃ ១,៦% ធៀបនឹងត្រីមាសមុន ។ ទល់នឹងប្រាក់បាតថៃ ប្រាក់រៀលធ្លាក់ថ្លៃ ០,៨% ដោយប្តូរបាន ១១៣,៧ រៀល/បាត ហើយទល់នឹងប្រាក់ដុងវៀតណាម វាឡើងថ្លៃ ១,១% ដល់ ២៤,៦រៀល/១០០ដុង ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ប្រាក់រៀលឡើងថ្លៃ ០,៨% ទល់នឹងដុល្លារUS និង ៣,២% ទល់នឹងប្រាក់ដុងវៀតណាម ហើយវាធ្លាក់ថ្លៃ ១០,០% ទល់នឹងប្រាក់បាតថៃ ។

## ការវិវត្តន៍រូបិយវត្ថុ

ទ្រព្យសកម្មក្នុងស្រុកសុទ្ធ រួមមាន ឥណទានក្នុងស្រុក និង "បំណុលផ្សេងៗ" ។ "បំណុលផ្សេងៗ" ជានិច្ចជាកាល មានសមតុល្យអវិជ្ជមានដោយសារវាជាបំណុលរបស់ប្រព័ន្ធធនាគារ ហើយសមាសភាពនេះជារឿយៗបណ្តាលឱ្យទ្រព្យសកម្មក្នុងស្រុកសុទ្ធ មានភាពអវិជ្ជមានផងដែរ ។ នៅត្រីមាសទី១ ២០០៧ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ មាន-២៦៣,១ពាន់លានរៀល ដែលជាចំនួនអវិជ្ជមាន ប៉ុន្តែកើនឡើង ៦៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០០៦ ក្នុងនោះ "បំណុលផ្សេងៗ" កើន ១៦% ដល់ ៣១៥៥,២ពាន់លានរៀល ។ រីឯឥណទានក្នុងស្រុក ក៏កើនដែរបាន ៤៣% ដល់ ២៨៩២,១ពាន់លានរៀល ដែលក្នុងនោះឥណទានរដ្ឋាភិបាល កើន ៧,៤% ដល់ ២៩៨,០ពាន់លានរៀល និងឥណទានឯកជន កើន ៤៦% ដល់ ៤០៦៧,៧ពាន់លានរៀល រីឯបញ្ញើរដ្ឋាភិបាលកើន ៤៣% ដល់ ១៤៧៣,៥ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធកើន ២៦% ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០០៦ ដល់ ៨០៥៦,៣ពាន់លានរៀល ។ ទ្រព្យសកម្មសុទ្ធរបស់ប្រព័ន្ធធនាគារបានផ្តល់នូវរូបិយវត្ថុទូទៅ (M2) ចំនួន ៧៧៩៣,២ពាន់លានរៀល រឺកើន ៣៦% ធៀបនឹងត្រីមាសទី១ ២០០៦ ។ រូបិយវត្ថុទូទៅ (M2) រួមមាន បំណុលរបស់ប្រព័ន្ធធនាគារដែលជារូបិយវត្ថុនៅក្រៅធនាគារ បានកើនឡើង ២៤% ដល់ ១៧៣៣,៦ពាន់លានរៀល បញ្ញើជាប្រាក់រៀលធ្លាក់ចុះ ៣,៩% មកត្រឹម ១៥៤,៨ពាន់លានរៀល និងប្រាក់បញ្ញើជារូបិយវត្ថុបរទេស កើន ៤២% ដល់ ៥៩០៤,៧ពាន់លានរៀល ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

នៅខែឧសភា ២០០៧ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ ចំនួន ១០ក្រុម កើន ១៦% ដល់ ៨២៤០រៀល ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០០៦ (មើលតារាង) ។ ទោះយ៉ាងនេះក្តី ប្រាក់ចំនូលរបស់កម្មករសំនង់គ្មានជំនាញ ធ្លាក់ចុះ ៥% និងរបស់អ្នកស៊ីឈ្នួលធ្វើស្រែ ធ្លាក់ចុះ ១% ។

ចំនូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប កើន ៤៧% ធៀបនឹងអំឡុងពេលដូចគ្នា ឆ្នាំ២០០៦ ដល់ ១២.៨០០រៀល ។ កំណើននេះដោយសារតែការធ្វើការច្រើនម៉ោង (១១ម៉ោងក្នុងមួយថ្ងៃ) និងមានតំរូវការខ្ពស់ ។ អ្នកឆ្លើយសំភាសន៍ ៦០% បានជួលផ្ទះ ១០% ស្នាក់នៅជាមួយបងប្អូន និងអ្នកផ្សេងទៀតមានផ្ទះនៅក្នុងទីក្រុង រឺនៅជាយក្រុង ។ ម្យ៉ាងទៀត អ្នករត់ម៉ូតូឌុប ៩៥% បាននិយាយថា គ្រួសាររបស់ពួកគេឥឡូវមានជីវភាពធូរធារ រីឯ ៥% ទៀតថាមិនមានភាពធូរធារអ្វីសោះ ចាប់តាំងពីពួកគេមកធ្វើការនៅទីក្រុង ។ អ្នករត់ម៉ូតូឌុប ៤៥% បានធ្វើការងារជាង៥ឆ្នាំហើយ ៣៧,៥% ធ្វើការបានពី ៣-៥ឆ្នាំ និង ១៧,៥% តិចជាង៣ឆ្នាំ ។ ពួកគេ ៩៥% បានរាយការណ៍ថា ប្រាក់ចំណូលរបស់ពួកគេមិនគ្រប់គ្រាន់សំរាប់បង្កើតមុខរបរថ្មីទេ ប្រសិនបើពួកគេចាកចេញពីការងារបច្ចុប្បន្ន ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ កើន ២១% ធៀបនឹងអំឡុងពេលដូចគ្នាមួយឆ្នាំមុន ។ កម្មករមានជំនាញ ៦៨% បានបង្ហាញថា គំរោងសាងសង់នៅទីក្រុងបានកើនឡើងយ៉ាងខ្លាំង ដូច្នេះមានការងារច្រើនជាងឆ្នាំមុន ។ កម្មករមានជំនាញចំណាយប្រហែល ៣៥០០រៀល សំរាប់អាហារប្រចាំថ្ងៃ និងប្រហែល ១៣០.០០០រៀលក្នុងមួយខែ ។ ពួកគេ ៩៥% មកពីជនបទ ហើយមាន ៤៥% នៅលីវ ។ ផ្ទុយទៅវិញ ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៥% ធៀបនឹងខែឧសភា ២០០៦ ។ អ្នកឆ្លើយសំភាសន៍ ៧៧% បាននិយាយថា មូលហេតុដែលធ្វើឱ្យចំណូលពួកគេធ្លាក់ចុះ គឺដោយសារតែកំណើននៃចំនួនកម្មករ ។ ទោះយ៉ាងនេះក្តី កម្មករគ្មានជំនាញ ៣៨% យល់ឃើញថា គ្រួសាររបស់ពួកគេមានជីវភាពធូរធារ តាំងពីពួកគេមកធ្វើការនៅទីក្រុង ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយមាន ៥៥៣៣រៀល រឺកើន ២៣% ធៀបនឹងអង្កេតមួយឆ្នាំមុន ហើយកើន ២២% ធៀបនឹងអង្កេតនៅ៣ខែមុន ។ អ្នករើសអេតចាយ ៦០% បានរាយការណ៍ថា ថ្លៃអេតចាយកើនឡើងនៅរយៈ៣ខែដល់ខែឧសភា ។ ពួកគេ ៩៥% បាននិយាយថា បើតាមចំណូលនេះ ពួកគេមិនអាចសន្សំប្រាក់ ដើម្បីបង្កើតមុខរបរថ្មីបានទេ ។ អ្នករើសអេតចាយ ៤៣% បានខ្ចីប្រាក់ពីឈ្មួញកណ្តាល រឺអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗនៅពេលគ្រួសារពួកគេខ្វះខាតម្ហូបអាហារ រឺមានជំងឺ ។

ចំណូលរបស់អ្នកធាក់ស៊ីក្លូ កើនឡើង ៨% ពី ៨៥៤៦រៀល នៅឆ្នាំមុន ដល់ ៩២៥០រៀល ។ អ្នកធាក់ស៊ីក្លូ បានចំនាយពេលច្រើនប្រហែល ១១ម៉ោងក្នុងមួយថ្ងៃ ដើម្បីបង្កើនប្រាក់ចំណូលរបស់ពួកគេ ។ អ្នកផ្សេងទៀត មានម៉ូយប្រចាំ ដែលជានិច្ចជាកាលជាពាណិជ្ជករនៅក្នុងផ្សារ ។ ទោះយ៉ាងនេះក្តី

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

អ្នកធាក់ស៊ីក្លូបានត្អូញត្អែរថា ពួកគេមិនអាចសន្សំប្រាក់បានគ្រប់គ្រាន់ ដើម្បីបង្កើតមុខរបរថ្មីផ្សេងទៀតទេ ។ ៥៥% ទៀតនិយាយថា ជីវភាពគ្រួសាររបស់ពួកគេនៅដដែល ១០%ទៀតថា មានភាពលំបាកជាងមុន និង ៣៥% ទៀតថា មានភាពល្អប្រសើរនៅពេលប្រកបរបរនេះ ។

ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាចមាន ៨៩៥០រៀល រឺកើន ៣៨% ធៀបនឹងខែឧសភា ២០០៦ ។ អ្នកលក់បន្លែតូចតាចចំនួន ១៨% នៅលីវ ហើយពួកគេដើរតួយ៉ាងសំខាន់ក្នុងការជួយផ្គត់ផ្គង់គ្រួសារ ។ ពួកគេភាគច្រើនបានរាយការណ៍ថា គ្រួសារពួកគេបានធូរធារតាំងពីពួកគេចាប់ផ្ដើមមុខរបរនេះ ។

ចំណូលរបស់កម្មករកាត់ដេរ កើន ៦% ធៀបនឹងមួយឆ្នាំមុន ដោយកើនពី ៧៨៦០រៀល ដល់ ៨៣៥០រៀល ។ ភាគច្រើននិយាយថា ពួកគេធ្វើការច្រើនជាង៤៨ម៉ោងក្នុងមួយសប្ដាហ៍ ។ កម្មករកាត់ដេរ ៤៦% បានរាយការណ៍ថា អាចរកបានពី៥៦ដុល្លារ-៧០ដុល្លារ/ខែ និង ២៦% ទៀតថា អាចរកបានច្រើនជាង ៧០ដុល្លារ/ខែ ។ អង្កេតបានបង្ហាញថា កម្មករកាត់ដេរ ៣៥% បានធ្វើការដដែលអស់រយៈពេលប្រហែលជាង៥ឆ្នាំហើយ ៣៩% ធ្វើការបានពី២-៥ឆ្នាំ ១២% ធ្វើការបាន១-២ឆ្នាំ និង ១៤% ធ្វើការបាន១ឆ្នាំ ។ កម្មករ ១៣% បានរាយការណ៍ថា អាចសន្សំប្រាក់បានមួយចំនួនដើម្បីផ្ដល់ទៅឱ្យគ្រួសារ រីឯកម្មករផ្សេងទៀតថា អាចផ្ដល់ប្រាក់ទៅឱ្យគ្រួសារ បានត្រឹមតែមួយរយៈប៉ុណ្ណោះ ។

អង្កេតបានបង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកបំរើតាមភោជនីយដ្ឋាន ធ្លាក់ចុះ ១% ធៀបនឹងខែឧសភា ឆ្នាំ២០០៦ ។ ពួកគេប្រហែល ៥៧% បានផ្ញើប្រាក់ទៅផ្ទះដើម្បីជួយផ្គត់ផ្គង់គ្រួសារ ដូច្នេះគ្រួសារពួកគេភាគច្រើន មានជីវភាពធូរធារជាងមុន ។

ចំណូលប្រចាំថ្ងៃរបស់អ្នកស៊ីឈ្នួលធ្វើស្រែនៅនឹងដដែលគឺ ៤៥៣០រៀល ធៀបនឹងអំឡុងពេលដូចគ្នាឆ្នាំ២០០៦ ។ អ្នកស៊ីឈ្នួលធ្វើស្រែ ៧០%និយាយថា ជីវភាពគ្រួសារពួកគេគឺនៅដដែល ។ ៦៥% ថា បានចំណាយភាគច្រើនលើម្ហូបអាហារ ហើយអ្នកផ្សេងទៀតថា គឺចំណាយលើការថែទាំសុខភាព ។ ម្យ៉ាងទៀត ៤៣% និយាយថា ពួកគេបានខ្ចីប្រាក់ពីម្ចាស់ដីស្រែដោយសងវិញតាមការលក់កំលាំងពលកម្មរបស់ពួកគេឱ្យម្ចាស់ដីស្រែទាំងនោះ ។

*រៀបរៀងដោយ*

*ប៊ុន ដូរីណា និង ផាន់ ដាលីស*

**តារាង ១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ១៩៩៩-២០០៧**

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 63.9 | 9.8 | 0.4 | 40.3 | 3.7 | 12.3 | 26.8 | 126.5 | 216.9 | 0.0 | 154.6 | 19.1 |
| ឧស្សាហកម្ម | 162.6 | 109.4 | 105.2 | 67.7 | 137.2 | 189.2 | 912.6 | 40.1 | 76.9 | 171.7 | 76.6 | 142.7 |
| កាត់ដេរ | 67.7 | 81.5 | 26.5 | 27.2 | 68.1 | 133.9 | 152.0 | 30.5 | 9.6 | 23.2 | 26.1 | 36.6 |
| សេវាកម្ម | 222.6 | 150.1 | 118.4 | 145.3 | 168.4 | 92.0 | 155.5 | 60.7 | 2,043.2 | 94.5 | 740.7 | 335.7 |
| សណ្ឋាគារ និងទេសចរណ៍ | 171.8 | 79.8 | 73.8 | 47.1 | 124.1 | 55.9 | 102.6 | 0.0 | 26.2 | 3.5 | 315.3 | 140.3 |
| សរុប | 449.1 | 269.2 | 224.0 | 253.3 | 309.3 | 293.5 | 1094.9 | 227.3 | 2,337.0 | 266.2 | 971.9 | 497.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | - | 90.7 | 928.1 | -88.6 | 265.1 | -48.8 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -47.6 | -40.0 | -16.8 | 13.1 | 22.1 | -5.1 | 273.0 | -52.2 | 2331.2 | -34.1 | 715.4 | 118.9 |

*Including expansion project approvals. Up to June 2006. Source: Cambodian Investment Board*

**តារាង ២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ១៩៩៩-២០០៧**

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 30.3 | 45.5 | 10.1 | 5.7 | 7.6 | 9.7 | 10.9 |
| ផ្ទះល្វែង | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 167.6 | 204.2 | 39.9 | 51.8 | 67.1 | 54.5 | 59.9 |
| ផ្សេងៗ | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 65.6 | 109.1 | 17.4 | 24.7 | 20.8 | 13.9 | 19.5 |
| សរុប | 326.9 | 205.4 | 196.3 | 219.9 | 198.9 | 263.5 | 358.8 | 67.4 | 82.2 | 95.5 | 78.2 | 90.4 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | - | -6.2 | 22.2 | 16.1 | -18.1 | 15.6 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 18.7 | -37.2 | -4.4 | 12.0 | -9.5 | 32.5 | 36.2 | -36.5 | -21.2 | 24.8 | 8.9 | 34.2 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង ៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៩-២០០៧

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 941.1 | 1056.2 | 1268.2 | 1453.2 | 1708.1 | 2108.1 | 644.8 | 603.2 | 652.5 | 807.5 | 736.7 | 707.8 |
| រួមមាន: សំលៀកបំពាក់ | 554.0 | 962.1 | 1202.2 | 1355.8 | 1628.4 | 2027.0 | 601.0 | 568.5 | 632.4 | 782.0 | 716.0 | 677.5 |
| - ទៅសហរដ្ឋអាមេរិក | 486.0 | 714.1 | 840.9 | 943.4 | 1099.8 | 1270.9 | 408.1 | 402.5 | 438.6 | 522.8 | 483.2 | 499.1 |
| - ទៅសហភាពអឺរ៉ុប | - | 228.1 | 323.3 | 356.3 | 414.7 | 590.8 | 145.3 | 110.6 | 142.2 | 188.1 | 160.1 | 106.3 |
| - ប្រទេសផ្សេងទៀត | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 165.3 | 47.5 | 55.3 | 51.6 | 71.0 | 72.8 | 72.0 |
| កសិកម្ម | - | 94.2 | 66.0 | 97.3 | 79.7 | 81.2 | 43.8 | 34.7 | 20.2 | 25.5 | 20.7 | 30.3 |
| - កៅស៊ូ | - | 29.6 | 25.9 | 29.7 | 35.1 | 38.3 | 13.4 | 7.8 | 9.8 | 13.6 | 10.2 | 8.4 |
| - ឈើ | - | 32.9 | 22.3 | 16.0 | 10.2 | 11.1 | 2.0 | 2.1 | 2.3 | 2.5 | 1.7 | 2.1 |
| - ត្រី | - | 5.4 | 6.0 | 4.3 | 2.8 | 10.6 | 6.6 | 1.9 | 1.0 | 1.6 | 1.4 | 0.7 |
| - ផ្សេងៗ | - | 26.2 | 11.8 | 47.4 | 31.6 | 21.3 | 21.9 | 22.9 | 7.0 | 7.7 | 7.5 | 19.0 |
| ការនាំចូលសរុប | 1237.4 | 1417.7 | 1501.4 | 1707.8 | 1824.9 | 2149.0 | 691.1 | 690.7 | 774.9 | 784.3 | 807.1 | 790.9 |
| រួមមាន: - សាំង | - | - | - | 25.9 | 33.2 | 30.2 | 10.7 | 10.9 | 12.4 | 13.1 | 13.2 | 15.7 |
| - ម៉ាស៊ូត | - | - | - | 100.8 | 109.6 | 109.4 | 21.1 | 32.5 | 32.2 | 30.1 | 27.2 | 31.9 |
| - សំភារៈសំណង់ | - | - | - | 12.9 | 80.8 | 95.3 | 26.2 | 37.0 | 39.1 | 42.5 | 35.8 | 44.1 |
| - ផ្សេងៗ | - | - | - | 1568.2 | 1601.3 | 1914.0 | 633.1 | 610.3 | 691.2 | 698.5 | 731.0 | 699.2 |
| ជញ្ជីងពាណិជ្ជកម្ម | -296.3 | -361.5 | -233.2 | -254.6 | -116.8 | -40.9 | -46.3 | -87.5 | -122.4 | 23.2 | -70.4 | -83.1 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | -15.3 | -5.4 | 11.2 | 23.7 | -8.4 | -5.4 |
| ការនាំចេញសរុប | - | - | - | - | - | - | -11.7 | -6.4 | 8.2 | 23.7 | -8.8 | -3.9 |
| ការនាំចូលសរុប | - | - | - | - | - | - | 9.3 | -0.03 | 12.2 | -1.6 | 5.9 | -2.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 24.5 | 15.5 | 27.8 | 27.1 | 10.2 | 19.1 | 19.2 |
| ការនាំចេញសរុប | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 23.4 | 18.3 | 30.3 | 26.7 | 10.6 | 14.3 | 17.3 |
| ការនាំចូលសរុប | 11.3 | 14.6 | 5.9 | 13.7 | 6.9 | 17.8 | 26.1 | 32.6 | 15.6 | 20.9 | 16.8 | 14.5 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF.*

## តារាង ៤. ចំនួនភ្ញៀវបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០៧

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | | 2007 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ភ្ញៀវពាន់នាក់ | | | | | | | | | | | |
| តាមផ្លូវអាកាស | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 626.1 | 856.5 | 275.4 | 204.4 | 224.2 | 325.0 | 373.6 |
| តាមផ្លូវគោក និងទឹក | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 428.9 | 565.1 | 181.9 | 153.6 | 146.4 | 191.0 | 177.2 |
| សរុប | 367.7 | 466.4 | 604.9 | 786.5 | 701.1 | 1055.0 | 1421.6 | 457.3 | 358.0 | 370.6 | 516.0 | 550.8 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 9.9 | -21.7 | 4.1 | 39.2 | 6.7 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 50.5 | 34.7 | 20.2 | 21.2 | 14.7 | 24.1 | 20.4 |

*Source: Ministry of Tourism*

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៩-២០០៧ (ពាន់លានរៀល)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | Q2 | Q3 | Q4 | Q1* |
| ចំណូលសរុប | 920 | 1326 | 1528 | 1530 | 1744 | 1764 | 2126 | 2625 | 731.5 | 732.2 | 1199.2 | 258.0 |
| ចំណូលចរន្ត | - | - | - | 1521 | 1728 | 1733 | 2107 | 2474 | 726.9 | 716.8 | 844.4 | 258.0 |
| ចំណូលពន្ធ | 676 | 956 | 1096 | 1096 | 1227 | 1220 | 1577 | 1911 | 558.6 | 565.8 | 661.3 | 222.5 |
| ពន្ធគយ | 376 | 432 | 376 | 376 | 424 | 395 | 513 | 5,73 | 151.7 | 157.2 | 200.0 | - |
| ពនកងតេក | - | - | - | - | - | - | - | - | - | - | - | 150.3 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | - | - | - | - | 72.2 |
| ចំណូលមិនមែនពន្ធ | 204 | 348 | 424 | 424 | 501 | 513 | 530 | 563 | 168.3 | 151.0 | 183.1 | 35.5 |
| អាជីវកម្មព្រៃឈើ | 20 | 36 | 28 | 29 | 15 | 7 | 2 | 3 | 0.7 | 0.3 | 0.9 | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 88 | 108 | 124 | 122 | 123 | 120 | 94 | 123 | 30.0 | 11.7 | 30.0 | - |
| ធំណពណេើអគពទេទេពរ | - | - | - | - | - | - | - | - | - | - | - | 2.9 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | - | - | - | - | 30.3 |
| ចំណូលជាមូលធន | 36 | 12 | 8 | 9 | 16 | 31 | 19 | 152 | 4.6 | 15.4 | 354.7 | 0.0 |
| ចំណាយសរុប | 1348 | 1788 | 2332 | 2332 | 2948 | 2757 | 2932 | 3295 | 1012.0 | 924.0 | 1078.4 | 101.7 |
| ចំណាយជាមូលធន | 368 | 624 | 976 | 977 | 1388 | 1171 | 1163 | 1328 | 386.6 | 317.2 | 349.8 | 76.0 |
| ចំណាយចរន្ត | 980 | 1164 | 1356 | 1355 | 1560 | 1586 | 1769 | 1967 | 625.4 | 606.9 | 728.7 | 25.8 |
| អប់រំ និងសុខាភិបាល | 132 | 280 | 344 | 343 | 454 | 473 | 518 | 351 | 202.3 | 150.1 | 281.3 | - |
| ការពារជាតិ និងសន្តិសុខ | 448 | 464 | 404 | 405 | 438 | 411 | 423 | 451 | 116.7 | 155.3 | 170.1 | - |
| ក្រសួងផ្សេងៗទៀត | 332 | 412 | 636 | 637 | 668 | 702 | 828 | 1165 | 306.4 | 301.5 | 277.3 | - |
| បៀវត្សរ៍ | 448 | 518 | 517 | 509 | 587 | 615 | 640 | 711 | 210.3 | 230.6 | 240.6 | 13.7 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | - | - | - | - | - | - | - | - | - | 4.0 |
| ឱនភាពទូទៅ | -428 | -462 | -804 | -802 | -1,204 | -993 | -806 | -706 | -280.5 | -191.9 | 120.7 | 65.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 268 | 416 | 768 | 766 | 1,249 | 886 | 864 | 1127 | 333.3 | 228.6 | 296.5 | 78.8 |
| ហិរញ្ញប្បទានក្នុងស្រុក | 112 | 60 | 36 | 37 | -45 | 106 | 148 | -396 | -52.8 | -36.7 | -417.2 | -261.3 |

*Provisional for 2007. Data available to January 2007.*

### តារាង ៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួល) អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ១៩៩៩-២០០៧

| | 1999 | 2000 | 2001* | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 14.4 | 16.4 | 15.8 | 12.0 | 8.5 | 7.2 | 4.3 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 3.9 | 5.8 | 6.1 | 4.5 | 4.9 | 3.4 | 3.0 |
| - ម្ហូបអាហារ | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 6.4 | 8.6 | 10.6 | 6.3 | 5.8 | 3.3 | 3.0 |
| - ដឹកជញ្ជូន | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 9.7 | 11.4 | 9.7 | 10.0 | 10.1 | 6.8 | 5.2 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ* | - | 3840.8 | 3916.3 | 3912.1 | 3973.3 | 4016.3 | 4119.7 | 4094.8 | 4106.6 | 4145.3 | 4129.4 | 4063.0 |
| រៀលក្នុង ១ បាតថៃ* | - | 95.8 | 88.2 | 91.1 | 95.8 | 99.9 | 102.6 | 103.5 | 108.0 | 110.3 | 113.0 | 113.7 |
| រៀលក្នុង ១០០ ដុងវៀតណាម* | - | 27.1 | 26.6 | 25.6 | 25.6 | 25.5 | 25.8 | 25.4 | 25.0 | 24.9 | 25.0 | 24.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 54.0 | 64.2 | 72.2 | 73.0 | 72.8 | 77.7 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1,065 | 1105 | 1329 | 1521 | 1508 | 2088 | 2633 | 2867 | 3110 | 3333 | 3250 | 3067 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,613 | 1760 | 2113 | 2084 | 2150 | 2833 | 3442 | 3767 | 4000 | 4200 | 4050 | 3750 |

*Sources: CDRI, IMF, NIS, Ministry of Planning, Ministry of Economy and Finance*

### តារាង ៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៩-២០០៧ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 Q1 | Q2 | Q3 | Q4 | 2007 Q1 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 2019 | 2589 | 3080 | 3737 | 4027 | 4797 | 5475 | 6410 | 6682 | 6958 | 7224 | 8056 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -576 | -759 | -876 | -849 | -698 | -467 | -450 | -699 | -637 | -497 | -282 | -263 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 103 | 3 | -75 | -119 | -128 | -209 | -421 | -755 | -831 | -892 | -953 | -1176 |
| ឥណទានចំពោះផ្នែកឯកជន | 763 | 898 | 936 | 1059 | 1337 | 1817 | 2394 | 2778 | 2997 | 3288 | 3628 | 4066 |
| រូបិយវត្ថុទូទៅ M2 | 1443 | 1830 | 2204 | 2888 | 3329 | 4330 | 5025 | 5711 | 6045 | 6461 | 6942 | 7793 |
| រូបិយវត្ថុ M1 | 531 | 540 | 609 | 813 | 937 | 1153 | 1323 | 1449 | 1512 | 1563 | 1658 | 1794 |
| រូបិយវត្ថុផ្សេងៗ | 912 | 1290 | 1595 | 2075 | 2392 | 3177 | 3702 | 4262 | 4533 | 4898 | 5285 | 5999 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 17.3 | 26.8 | 20.4 | 31.0 | 15.2 | 30.0 | 16.1 | 27.0 | 30.6 | 29.4 | 38.2 | 36.5 |
| រូបិយវត្ថុ M1 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 23.0 | 14.7 | 20.9 | 24.4 | 22.2 | 25.3 | 23.9 |
| រូបិយវត្ថុផ្សេងៗ | 32.7 | 41.4 | 23.6 | 30.0 | 15.2 | 32.8 | 16.6 | 33.6 | 32.8 | 31.9 | 42.7 | 40.7 |

*Source: National Bank of Cambodia*

### តារាង ៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2003 | 2004 | 2005 | 2006 | | 2007 | | | 2006 | 2007 | |
| | វិច្ឆិកា | | | | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | វិច្ឆិកា | កុម្ភៈ | ឧសភា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 8546 | 6063 | 7393 | 6534 | 9245 | -5 | -17 | 8 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7375 | 5238 | 7045 | 6010 | 9798 | 9 | -8 | 33 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6492 | 5197 | 6125 | 6125 | 11178 | -27 | -1 | 38 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 4512 | 4266 | 3903 | 4530 | 5533 | -19 | -9 | 23 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4243 | 4292 | 4498 | 4078 | 5150 | 16 | -13 | 21 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4541 | 4137 | 4653 | 4126 | 4278 | 10 | 0 | 0 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 7860 | 9264 | 8957 | 11146 | 8347 | 3 | 21 | 6 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8790 | 6744 | 8386 | 9144 | 12886 | -13 | 3 | 47 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6407 | 6028 | 5263 | 5094 | 6075 | -21 | -15 | -5 |
| កម្មករសំណង់មានជំនាញ | 13127 | 13111 | 12679 | 10316 | 9833 | 9466 | 10215 | 10146 | 11892 | -9 | -14 | 21 |

** Waitresses’ earnings do not include meals and accommodation provided by shop owners.*
*Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motocycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗពី...**

## ផ្នែកស្រាវជ្រាវ

នៅថ្ងៃទី២០-២១ សីហា ២០០៧ បណ្ដាញវិភាគអភិវឌ្ឍន៍ បានជួបប្រជុំនៅទីក្រុងភ្នំពេញ ដើម្បីពិភាក្សាអំពីវិធីសាស្ត្រចុះស្រាវជ្រាវតាមដានខ្សែរយៈទីផ្សារនៃដំណាំកៅស៊ូ ដំឡូងមី និងបសុសត្វ ។ នៅថ្ងៃទី២៩ សីហា ផ្នែកអភិបាលកិច្ច បានបើកសិក្ខាសាលាបំផុសគំនិត ដើម្បីដាក់ដំណើរការកម្មវិធីស្រាវជ្រាវស្ដីពីអភិបាលកិច្ច និងកំណែទំរង់សាធារណៈ ។ នៅថ្ងៃបន្ទាប់ទី៣០ សីហា ២០០៧ CDRI បានសហការរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ស្ដីពីដំណោះស្រាយរបស់មនុស្សពេលជួបគ្រោះធម្មជាតិដែលជាការងារស្ថិតក្នុងគំរោងវិភាគបញ្ហាអភិវឌ្ឍន៍របស់ CCC (ADI/CCC) ។ នៅថ្ងៃទី១២-១៣ កញ្ញា CDRI បានសហការជាមួយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) រៀបចំវេទិកាជួបជុំដៃគូទាំងអស់របស់ IDRC ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការកំណត់គោលដៅផ្ដល់ជំនួយស្រាវជ្រាវរបស់ IDRC ដល់កម្ពុជា ។

ទាក់ទិននឹងគំរោងស្រាវជ្រាវ ការសិក្សាអំពីការចាកផុតពីភាពក្រីក្រ បានចប់រួចរាល់ និងបានបោះពុម្ពផ្សាយរបាយការណ៍នៅខែកញ្ញា ។ គំរោងថ្មីមួយទៀតស្ដីពី ពាណិជ្ជកម្ម និងបរិស្ថាន បានចាប់ដំណើរការ នៅខែកញ្ញាដោយទទួលបានមូលនិធិពីបណ្ដាញចំណេះដឹងពាណិជ្ជកម្ម ដែលមានទីចាត់ការធំនៅក្រុងហ្សឺណែវ ។

# ព័ត៌មានថ្មីៗ ពី CDRI-វបសអ

## ការគ្រប់គ្រង

ពីថ្ងៃទី២-៤ កក្កដា ២០០៧ លោក Larry Strange នាយកប្រតិបត្តិ CDRI បានចូលរួមក្នុងសន្និសីទមួយរៀបចំឡើងដោយក្រុមគិតគូរឯកជនរបស់អាមេរិកឈ្មោះ Stanley Foundation ស្តីពីជំនួយពាណិជ្ជកម្ម និងហេដ្ឋារចនាសម្ព័ន្ធ: ទិដ្ឋភាពសេដ្ឋកិច្ចនៃកំលាំងចលករថ្មីនៅអាស៊ីអគ្នេយ៍នៅខេត្តសៀមរាប ជាមួយនឹងគណៈប្រតិភូកម្ពុជាជាច្រើននាក់ ជាអាទិ៍ សម្តេច នរោត្តម សិរីវុឌ្ឍ ប្រធានវិទ្យាស្ថានកម្ពុជាដើម្បីកិច្ចសហប្រតិបត្តិការ និងសន្តិភាព (CICP) ដែលជាសហអ្នករៀបចំ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ឯកឧត្តម ហង់ ជួន ណារ៉ុន អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃ CDRI និងឯកឧត្តម អេង វ៉ូឡង់ ឯកអគ្គរាជទូតគោចរនៃព្រះរាជាណាចក្រកម្ពុជា ។ ផ្អែកតាមកិច្ចពិភាក្សាក្នុងសន្និសីទ Stanley Foundation នឹងរៀបចំសេចក្តីសង្ខេបសំរាប់គោលនយោបាយ សំដៅក្បៀងគរការចូលរួមកាន់តែសក្តិសិទ្ធិពីសហរដ្ឋអាមេរិកនៅទូទាំងអាស៊ីអគ្នេយ៍ ដោយផ្តោតពិសេសលើអ្នកកសាងគោលនយោបាយក្នុងរដ្ឋការថ្មីរបស់អាមេរិកនៅចុង២០០៨ និងដើម ២០០៩ ។

ក្រុមប្រឹក្សាភិបាលរបស់ CDRI បានធ្វើការប្រជុំពាក់កណ្តាលឆ្នាំរបស់ខ្លួនកាលពីថ្ងៃទី១១ សីហា ២០០៧ ។ ក្រុមប្រឹក្សាបានគាំទ្រដល់ការជូនមតិរបស់ថ្នាក់គ្រប់គ្រងនៃ CDRI ដែលស្នើថា ពីពេលនេះរហូតដល់ចុងបញ្ចប់នៃផែនការយុទ្ធសាស្ត្រឆ្នាំ២០០៦-១០ គួរផ្តោតការប្រឹងប្រែងថែមទៀតលើការផ្សព្វផ្សាយចែកចាយ និងផលប៉ះពាល់នៃឯកសារខាងគោលនយោបាយ និងឯកសារស្រាវជ្រាវជាភាសាខ្មែរ ជាពិសេសសំរាប់អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជន និងសង្គមស៊ីវិល ។ ក្រុមប្រឹក្សាភិបាល ក៏បានសំរេចបង្កើតក្រុម "មិត្តគាំទ្រ" និង "ជនឆ្នើម" របស់ CDRI ដើម្បីទទួលស្គាល់គុណបំណាច់របស់ជនវិសេសៗនៅក្នុងប្រទេសកម្ពុជានិងនៅបរទេស ដែលបានចូលរួមចំណែកជួយដល់ការងាររបស់ CDRI និងលើកកំពស់ការប្រើប្រាស់យោបល់ និងការគាំទ្រផ្សេងៗរបស់អ្នកទាំងនេះ ។ ក្រុមប្រឹក្សាភិបាល ក៏បានអនុម័តលើផែនការសំរាប់សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៨ ដែលគ្រោងធ្វើឡើង នៅចុងខែកុម្ភៈ ២០០៨ ដោយរួមសហការជាដៃគូជាមួយធនាគារ ANZ Royal ។ សន្និសីទគ្រោងផ្តោតលើប្រធានបទ "ការកេណ្ឌប្រមូលធនធាននៅកម្ពុជា - ធនធានមនុស្ស ធម្មជាតិ ហិរញ្ញវត្ថុ - សំរាប់ការអភិវឌ្ឍន៍ ការរីកលូតលាស់ និងវិបុលភាព" ។

ស្របតាមការតាំងចិត្តធ្វើការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ ឱ្យបានសក្តិសិទ្ធិដល់អង្គការសង្គមស៊ីវិលនៅកម្ពុជា នៅថ្ងៃទី៣១ សីហា ២០០៧ CDRI បានសហការរៀបចំសិក្ខាសាលាសង្ខេបរបាយការណ៍មួយស្តីពី "ការប្រែប្រួលជីវភាពនៅជនបទ ដោយសារគ្រោះមហន្តរាយ និងការប៉ះទង្គិចធ្ងន់ធ្ងរ" ដោយសហការជាមួយគំរោងវិភាគបញ្ហាអភិវឌ្ឍន៍របស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ក្នុងនេះមានការបង្ហាញពីលទ្ធផលសំខាន់ៗនៃការសិក្សាថ្មីៗ ស្តីពីការវាយតំលៃភាពក្រីក្រដោយមានការចូលរួមនៅជុំវិញបឹងទន្លេសាប និងការចាកផុតភាពក្រីក្រ ។

នៅភ្នំពេញ កាលពីថ្ងៃទី១២-១៣ កញ្ញា CDRI បានរួមគ្នាជាមួយវិទ្យាស្ថានសិក្សាពីការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ ដើម្បីរៀបចំវេទិកាជួបជុំដៃគូនៅកម្ពុជារបស់ មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) ដោយប្រមូលដៃគូកម្ពុជាទាំងអស់របស់ IDRC មកជួបប្រជុំពិភាក្សាពី វិធីសាស្ត្រសំរបសំរួលដើម្បីបំពេញតំរូវការស្រាវជ្រាវខាងអភិវឌ្ឍន៍នៅកម្ពុជា ។ IDRC ជាដៃគូយូរអង្វែង និងផ្តល់ការគាំទ្រយ៉ាងខ្លាំងរបស់ CDRI ជាពិសេសលើបញ្ហាពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងក្នុងអនុតំបន់ បញ្ហាធនធានធម្មជាតិនិងបរិស្ថាន ទាំងនៅកម្ពុជា នៅមហាអនុតំបន់មេគង្គ និង នៅអាស៊ីអគ្នេយ៍ ។

*តទៅទំព័រទី ១៩*

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១១ លេខ៣ ខែកក្កដា_កញ្ញា ឆ្នាំ២០០៧

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ សំរាប់ពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពល ដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្តល់ការវាយតំលៃឯករាជ្យស្តីពីដំណើរវិវត្តន៍នៃសេដ្ឋកិច្ចកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវមានចុះហត្ថលេខាប្រត្យក្សភាព លេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទងមក CDRI-វបសអ មុននឹងផ្តល់អត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ CDRI-វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយពុំមានបញ្ជាក់ហេតុផល ។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, (៨៥៥-១២) ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh, http://www.cdri.org.kh

គ្រឹះស្ថានផ្សាយ: វិទ្យាស្ថាន CDRI
គ្រប់គ្រងកែសំរួល: យូ សិទ្ធីរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា
ជំនួយការកែសំរួល: យេន សុផានី និង គីម ចិត្រា
រូបភាពទំព័រមុខ: CDRI

បោះពុម្ព នៅរោងពុម្ពជប៉ុន ភ្នំពេញ

© រក្សាសិទ្ធិ ២០០៧ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ CDRI-វបសអ ទេ ។